សារព័ត៌មាន ខ្មែរផុស ស.រ.អា
KhmerPost USA
E-mail: info@khmerpost.us / Website : khmerpost.us
Advertising: 978-656-8141/ Hotline news: 978-942-1641

មាតិការរឿង

Issue 161 Sept 08th-21.th, 2014

Free

១-កិច្ចពិភាក្សានៅ"យូម៉ាសឡូ"របស់.......... ......០២
៣-មនុស្ស៤នាក់សរភាពពីកំហុស........ .............០៣
៤-ព្រះសង្ឃបណ្តេញសមាជិកសភាគណបក្ស.........០៧
៥-វិស្សមកាលចុងរដូវក្តៅនៅរ៉ូដអាឡិន.............០៩
៦-ផ្តើមសម្តែងរដូវ២០១៤-១៥.........................០៨
៧-អតីតនាយករដ្ឋមន្ត្រីគាំទ្រការកំណត់................១២
៨-តុលាការចោទប្រកាន់បុរសវៀតណាម៧នាក់.....១២
៩-ល្មមភ្ញាក់ខ្លួនហើយ ហើយនាំគ្នាសាងទំព័រ..........១៥

New Office: Tel: (978) 677-7163 Fax: (978) 677-7092
45 Merrimack St. Suite 218A Lowell, MA 01852

# បោះឆ្នោតបឋមនៅថ្ងៃ ៩កញ្ញា ២០១៤

# Primary Election on September 9, 2014

បោះឆ្នោតបឋមនៅរដ្ឋម៉ាសាឈូសែតធ្វើឡើងនៅថ្ងៃទី៩ កញ្ញា ២០១៤។ ការិយាល័យបោះឆ្នោតនឹងបើកទ្វារពីម៉ោង៧ព្រឹកដល់ម៉ោង៨ល្ងាច ។ ដោយសារតែនេះជាការបោះឆ្នោតបឋមម្ល៉ោះហើយនៅក្នុងថ្ងៃតែមួយមានការឆ្នោត២យ៉ាងដាច់ពីគ្នាៈ គឺគណបក្សប្រជាធិបតេយ្យបឋម និងគណបក្សសាធារណរដ្ឋបឋម។ នៅពេលទៅបោះឆ្នោតបើអ្នកចុះឈ្មោះជាប្រជាធិបតេយ្យគេនឹងឱ្យអ្នកទៅបោះឆ្នោតហិបប្រជាធិបតេយ្យ-បើអ្នកចុះឈ្មោះជាសាធារណរដ្ឋគេនឹងឱ្យអ្នកបោះឆ្នោតហិបសាធារណរដ្ឋ -បើអ្នកមិនទាន់បានជ្រើសយក១ណានៅឡើយ អ្នកត្រូវជ្រើសយកហិបបោះឆ្នោតណាមួយមកប្រើ។

ឆ្នាំនេះមានការិយាល័យសំខាន់ៗជាច្រើនចេញដាក់ឱ្យបោះឆ្នោត ។ មានករណីខ្លះបេក្ខជនដែលបន្តកាន់ការការិយាល័យគ្មានអ្នកប្រឆាំងពីគណបក្សខ្លួនឯង ដូច្នេះមានឈ្មោះលេចចេញមកនៅលើហិប ហើយអ្នកអាចនឹងបោះឆ្នោតឱ្យបាន ។ នៅពេលដែលមានបេក្ខជនតែ១ គេហៅថាគ្មានអ្នកប្រឆាំងនៅកន្លែងខ្លះទៀតមានអ្នកប្រឆាំងដល់ទៅ២-៣នាក់។ ទោះជាយ៉ាងណាក៏ដោយឈ្នះឆ្នោតថ្ងៃ៩ កញ្ញា ហើយគ្រាន់តែជាតំណាងគណបក្សខ្លួនឯងទេ រីឯឈ្នះឆ្នោតថ្ងៃទី ៤វិច្ឆិកា ទើបបានជាតំណាងរដ្ឋ ។

## ខាងក្រោមនេះជាការិយាល័យមានឈ្មោះនៅលើហិបឆ្នោត ហើយនឹងបេក្ខជនឈរឈ្មោះឱ្យគេបោះថ្ងៃ ៩ សីហា

Here are the offices that are on the ballot and the candidates who are running for them on September 9, First the Democrats:

U.S. Senator - **Edward Markey** -unopposed. Markey was elected last June to fill the term of John Kerry who became Secretary of State. Markey must now run for a full six year term.



២-អ៊ែដ ម៉ាគី
Ed Markey

Congress - **Niki Tsongas** - un posed. Tsongas was elected in 2007 and is a candidate for re-election this year.



៣-នីគី ត្សងហ្គាស
Niki Tsongas

Governor- the chief executive of Massachusetts. Current Governor Deval Patrickis not running for re-election. The candidates seeking to take his place are **Martha Coakley, Steve Grossman** and **Don Berwick.**



២- ម៉ាសា ខូកលី
(Martha Coakley)



១-ស៊ីវ ក្រសមែន
(Steve Grossman)



៣-ដុន ប៊ើវិក
(Don Berwick)

Lieutenant Governor - becomes Governorif the Governor is unable to serve. Our last Lieutenant Governor, **Tim Murray,** resigned in 2013 and was not replaced. The candidates running for Lieutenant Governor are **Steve Kerrigan, Mike Lake** and **Leland Cheung.**



២- ម៉ៃខ៍ ឡេក
(Mike Lake)



១- ស៊ីវ ខឺរីហ្គែន
(Steve Kerrigan)

Treasurer - in charge of the state's bank accounts and the state lottery. The current Treasurer, Steve Grossman, is running for Governor. The candidates running for Treasurer are **Barry Finegold, Deb Goldberg** and **Tom Conroy.**



៣- លីឡែន ឈឹង
(Leland Cheung)



៣- ប៉ើរី ហ្វាញហ្គោល
(Barry Finegold)



១- ឌិប ហ្គលប៊ឺដ
(Deb Goldberg)

Attorney General -the state's chief lawyer. The current Attorney General, Martha Coakley, is running for Governor. The candidates



២- ថម ខុនរ៉យ
(Tom Conroy)

**Continued to page 06**

## វិចារណកថា

# ឡូវែលនឹងបោះឆ្នោតឱ្យខ្មែរ



ពិន សំខុន

**ដោយ : ពិន សំខុន**

ខ្មែរផុសស.រ.អា.បានចូលរួមយ៉ាងសកម្មក្នុងការបោះឆ្នោតនៅឡូវែលលើកនេះដោយបានធ្វើការផ្សព្វផ្សាយច្រើនជ្រុងជ្រោយអញ្ជើញបេក្ខជនឱ្យមកពិភក្សាគ្នាជូនអ្នកបោះឆ្នោតស្តាប់ពីសមត្ថភាពនៃអ្នកឈរឈ្មោះធ្វើវិភាគដើម្បីឱ្យងាយស្រួលវាយតម្លៃប្រៀបធៀបគ្នាបាន ។

**ហេតុអ្វី? ពីព្រោះតែ**

-សង្កាត់"មីឌុលសិច១៨"នេះ ជាទីប្រជុំខ្មែរដ៏ច្រើនជាងគេបង្អស់នៅសហរដ្ឋអាមេរិកនេះ ។

-ខ្មែរឡូវែលកំពុងប្រឹងប្រែងខ្លាំងណាស់ ដើម្បីឱ្យក្លាយជាខ្មែរអាមេរិកាំងពិតៗត្រូវនាំគ្នារស់នៅលើទឹកដីនៃសំណាងថ្មីឱ្យបាន ។

-ពេលនេះជាឱកាសដ៏មានអំណោយផលបំផុត ដែលមតិជាច្រើនទាំងខ្មែររួមទាំងបរទេសយល់ថា គួរតែមានជនជាតិភាគតិចជាតំណាងតំបន់របស់ខ្លួន ។

-ភាពគ្មានដំណាងក្នុងតំបន់ដែលជនជាតិភាគតិចជាមតិភាគច្រើន គឺភាពអាម៉ាសមួយដែលគួរតែកែតម្រូវឱ្យបាន ។

**លទ្ធផលនៃការបង្ហាញៈ** បន្ទាប់ពីតាមដាននៅលើសំនួរដេញដោលទាំង២លើកនឹងពិគ្រោះគ្នាប្រជាពលរដ្ឋអ្នកបោះឆ្នោតអាចមើលឃើញថាសមត្ថភាពបេក្ខជនណាមួយដែលគេចូលចិត្តជាងគេតែក៏បានឃើញដែរថា បេក្ខជនខាងខ្មែរក៏មានសមត្ថភាពខ្ពស់មិនចាញ់អ្នកឯទៀតទេ ។ ខ្មែរជាច្រើនដែលបានតាមដានសំនួរចម្លើយបានធ្វើការវិនិច្ឆ័យហើយវាយតម្លៃចាប់យកបេក្ខជនតែម្នាក់របស់ខ្លួនរួចហើយកាសែត"ឡូសាន់"នឹងកាសែត "បូស្តុនហេរ៉ូល" បានសម្តែងការគាំទ្រដល់បេក្ខជនរ៉ាឌីម៉មបន្ទាប់ពីកិច្ចពិភក្សាទី២រួចមក។ មុននេះបន្តិចសហជីពដ៏ធំមួយនៃអ្នកបំរើការងារក្នុងរដ្ឋាភិបាលនៅរដ្ឋម៉ាសាឈូសែតក៏ផ្តល់ការគាំទ្រដល់ រ៉ាឌីម៉ម ដែរ ។សញ្ញាទាំងប៉ុន្មាននេះទំនងជាអាចបន្ថយការរារែករបស់សហគមន៍ខ្មែរដែលពិបាកជ្រើសយកបេក្ខជនខ្មែរតែម្នាក់នោះបានហើយ ពីព្រោះសញ្ញា

**តទៅទំព័រទី ០៨**

# កិច្ចពិភក្សានៅ"យូម៉ាសឡូ"របស់បេក្ខជនដំណាងរដ្ឋសង្កាត់"មីឌុលសិក១៨"

# 18th Middlesex Rep debate at UMass Lowell

**By Richard Howe Jr.**

ខ្ញុំបានចូលរួមស្តាប់កិច្ចពិភក្សាទល់មុខរបស់បេក្ខជនតំណាងរដ្ឋនៅសង្កាត់"មីឌុលសិច១៨" ដែលធ្វើនៅល្ងាចថ្ងៃទី៤កញ្ញានេះ នៅ"យូម៉ាសឡូ" អាគា"យូនីវើរស៊ីទីក្រុសឹង"ទើបសង់ថ្មី។ បន្ទទៅនេះជាកំណត់ហេតុដែលកតត្រាដោយយល់ក្នុងពេលកំពុងពិភាក្សាពុំមែនបកប្រែតាមពាក្យទេ ដែលនឹងផ្តល់ខ្លឹមសារត្រឹមត្រូវថា នរណានិយាយអំពីអ្វី?

លោកនាយកមហាវិទ្យាល័យ"មីហេន"បានស្វាគមន៏ភ្ញៀវអ្នកស្តាប់ដ៏ច្រើន (ប្រមាណ២០០នាក់) ហើយបកស្រាយពីសារសំខាន់នៃការបោះឆ្នោតនេះសម្រាប់សាលារៀន។ លោកបានលើកឡើងពីតំបន់ខ្លះដែលមានជនជាតិភាគតិចរស់នៅតែមានសម្លេងភាគច្រើននៅក្នុងប្រទេសហើយ "យុនីវើរស៊ីទីក្រុងសឹង" គឺជាអាគាសាធារណដែលស្វាគមន៏អ្នកជិតខាងដែលមិនមែនជាមនុស្សក្នុងមហាវិទ្យាល័យ។

អ្នកដឹកអង្គប្រជុំជាពិធីករ គឺ "ប្រែងថលតី" អ្នកតាំងសំនួរគឺ **១-**"គ្រីសស្កត"មកពីឡូសាន់ **២-**សុបិនពិនមកពីខ្មែរផុសស.រ.អា **៣-**"ហ្វីល ជប្រេហ្វយ"និស្សិតយូម៉ាសឡូ។

ពិធីករបានណែនាំឱ្យស្គាល់បេក្ខជន **១-**ប្រេត បាហ៊ូ **២-**ប្រាអិនដូណូវេន **៣-**ជីម លើរី **៤-**រ៉ាឌី ម៉ម **៥-**ដេវអាវឡេត **៦-**ផល រដ្ឋាយ៉ែម។ សំនួរនឹងសំចៅទៅបេក្ខជនទាំងអស់រយៈពេលសម្រាប់ឆ្លើយមានទន់ភ្លន់ខ្លះដែរ។

I attended the debate of the candidates for the 18th Middlesex Representative District which was held this evening at UMass Lowell's new University Crossing building. The following are the notes I took during the debate. It's not a verbatim transcript but it gives you a pretty accurate account of who said what:

Chancellor Meehan welcomes large audience and talks about the importance of this legislative district to the University. Mentions this is one of the few majority minority districts in the Commonwealth. University Crossing is a public building to which non University neighbors are welcome. Moderator is Frank Talty. Panelists are Chris Scott of Lowell Sun; Soben Pin of KhmerPost USA; and Phil Geoffroy, Umass Lowell student trustee.

Moderator Frank Talty introduces the candidates: Fred Bahou; Brian Donovan; Jim Leary; Rady Mom; Dave Ouellette; and Paul RathaYem. Questions will go to all candidates. Length of time somewhat flexible.

អង្គប្រជុំពិភក្សានៅ"យូម៉ាសឡូ"របស់បេក្ខជនដំណាងរដ្ឋសង្កាត់"មីឌុលសិក១៨"នេះ រៀបចំឡើងដោយ"ឡូសាន់"នឹង"យូម៉ាស់ឡូ"។

សូមអញ្ជើញអានសំនួរនឹងចម្លើយដែលយើងសូមជូនជាភាសាដើមដូចតទៅ

**Fred Bahou, Brian Donovan, Rady Mom, Jim Leary, Dave Ouellette, Paul RathaYem**



Fred Bahou, Brian Donovan, Rady Mom, Jim Leary, Dave Ouellette, Paul RathaYem




១-"គ្រីសស្កត"មកពីឡូសាន់ ២-សុបិនពិនមកពីខ្មែរផុសស.រ.អា ៣-"ហ្វីល ជប្រេហ្វយ"និស្សិតយូម៉ាសឡូ។

Chancellor Marty Meehan
Frank Talty
University Crossing at night
September 4, 2014

First question by Chris Scott: If you're elected, would you vote to give Robert DeLeo another term as House Speaker?

Fred Bahou: As an innersoled candidate I'd have to think about it. He's moved the state forward in a few areas, especially the casino bill which I support. However, I know the probation department was a problem. I'd have to work with our delegation and would have to look at it closely and intuitively.

**Brian Donovan:** Speaker DeLeo has done a great job. He's had some issues with DYS and Probation. He was tainted by that. But I would support him. He's done a good job in other areas.

**Jim Leary:** I would support Speaker DeLeo. There are issues that need to be addressed but I'd like to sit down with the delegation and the city administration and see what the city's priorities are.

**Rady Mom:** I would vote for MrDeLeo. I look forward to working with everyone in our delegation.

Dave Ouellette: Yes, I would support Mr. DeLeo.

**Paul RathaYem:** I know Mr. DeLeo from when I lived in Winthrop and I support him. My personal relationship with him might be helpful for Lowell.

Next Question by Soben Pin: What is your position on the new courthouse?

**Bahou:** It was worked on a number of years ago. The current courthouse is beat up. The new court would create an economy around it and it would lead to the creation of new businesses.

**Donovan:** Should stick with the existing plan. It will be a great boon to the city. It will draw businesses into the area. Current facilities need to be replaced.

**Leary:** In favor of it but it's important to be aligned with the city government's objectives. It's location will help tie in other parts of the city like Cambodia Town and Umass Lowell. It all works together.

**Mom:** When I first came to Lowell my bedroom overlooked the Hamilton Canal district. It didn't look that great. This is an exciting project and the city needs to pursue it.

**Ouellette:** Is in favor of courthouse. As a gateway city we have to develop all of these areas. We have to connect the Acre and Umass Lowell to all of these projects.

**Yem:** I'm the secretary of the Cambodia Town committee and we've been trying to connect Cambodia Town to the judicial center area and the rest of downtown. There are 340 businesses in Cambodia town with tremendous employment and economic opportunities.

Follow up question by Frank Talty. Mentions the existing courthouses that will be vacated. What should be done with them?

**Donovan:** It will be expensive to upgrade them. It should be a partnership between the city and state. They're important parcels so they should be developed.

**Leary:** Cites conversation with Jim Cooney a neighbor to Superior Courthouse about what a shame it would be to lose it. We should start discussing reuse now.

**Mom:** I worked near the Juvenile Court house. It's a beautiful building. We need to work on the funding and should all work together to get the needed funding.

**Ouellette:** It could be vibrant housing. I'm on the board of Coalition for a Better Acre for housing. We've done several successful projects. I'd explore funding and partnerships for that building.

**Yem:** I love these old buildings. I have experience redeveloping older buildings. We have enough affordable housing so I'd prefer it be used for something besides that.

**Bahou:** It hasn't been attended to and it should be preserved but we have to think about what will be most cost effective. I think we'll have more students moving in to Lowell so housing will tighten up so that might be the best use for it. Says it also might be used for a school admin building for

**Continued to Page 04**

ព័ត៌មានខ្លីៗ

# មនុស្ស៤នាក់សារភាពពីកំហុសលួចបន្លំ

**ឡូវែល:** ក្រុមគ្រួសារ៤នាក់នៅឡូវែលបានសារភាពទៅតុលាការថាបានបន្លំលាក់ប្រាក់២៥លានដុល្លាពី IRS -នេះជាព័ត៌មានផ្សព្វផ្សាយកាលពីថ្ងៃ២៨សីហា ដោយឡូវែលសាន់ ។

ដំណឹងនេះទាក់ទងពិឡើងតុលាការរបស់អ្នកស្រីម៉ាគ្គារែតម៉ាទេសកាលពីខែកញ្ញាឆ្នាំមុនចោទប្រកាន់ដោយមេធាវីរដ្ឋាភិបាលកាមែនអទីសដែលថា បានបន្លំប្រាក់ជាប់ពន្ធដែលជាប្រាក់កំរៃកម្មករចំនួន២៥លានដុល្លា នាចន្លោះឆ្នាំ២០០៤-២០០៩ នៅក្នុងនោះក៏មានប្រាក់ធានារ៉ាប់រងការងារដល់ Workers Compensation assurer ជាទឹកប្រាក់ចំនួន៨៨ម៉ឺនដុល្លាថែមទៀត ។

ខ្មែរផុសស.រ.អា.បានសាកសួរអ្នកស្រីនៅពេលនោះហើយបានទទួលចម្លើយមកវិញថារឿងនេះជារឿងចាស់ដែលលោកស្រីបានសងគេរួចសព្វគ្រប់ហើយមិនដឹងជាហេតុអ្វីក៏រឿងនេះលេចឡើងមកវិញ?

ការផ្សាយលើកនេះមានភាពច្បាស់លាស់ថាលោកស្រីម៉ាទីសរួមមានសមាជិកគ្រួសារ៤រូបបានសារភាពស្របនឹងការចោទប្រកាន់ពីការរួមគំនិតបំបាត់ប្រាក់កំរៃកម្មករដោយប្រើប្រពន្ធធានាគារចំនួន២០គណនីយមែន ។

ទាំង៤នាក់បានសារភាពកាលពីថ្ងៃព្រហស្បត្តិ៍ទី២៧ ពីបទរួមគំនិតបន្លំប្រាក់ពន្ធ-ក្លែងបន្លំសេចក្តីរាយការណ៍-បំពានច្បាប់...។ អ្នកទាំង៤នឹងទទួលការចោទប្រកាន់ជាផ្លូវការនៅថ្ងៃ២៤ខែវិច្ឆិកាតខាងមុខពីចៅក្រមម៉ាកអិលវ៉ុល ។ ខ្មែរផុសស.រ.អា.បានទូរស័ព្ទសាកសួរព័ត៌មានបន្ថែមពីអ្នកជាប់ចោទតែពុំបានទទួលចម្លើយថ្មីទេដោយទូស័ព្ទបានប្តូរអស់ទៅហើយ ។

នៅឡូវែលក៏ដូចជាតំបន់ឯទៀតនៃស.រ.អា។ នេះមានការងារជាច្រើនបានផ្តល់ឱ្យសហគមន៍ជនជាតិភាគតិចដើម្បីរស់ជាការងារដែលផ្តល់កំរៃតិចតួចជាទូទៅមិនបានដល់កំរិតទាបបំផុតនៃការរស់នៅប្រចាំថ្ងៃផង ។ ការងារនេះបានត្រូវរដ្ឋបន្ធការតឹងតែងក្នុងការត្រួតពិនិត្យធ្វើឱ្យសហគ្រាសអាចដកដង្ហើមបានខ្លះនៅពេលមានវិបត្តសេដ្ឋកិច្ចចំណែកអ្នករកការងារធ្វើក៏រីករាយនឹងមានការធ្វើបើទោះជាបានកំរៃតិចតួចក៏ដោយវិបត្តសង្គមក៏ចុះថយអ្នករកស៊ីនាំមនុស្សទៅធ្វើការក៏មានប្រយោជន៍។ នៅពេលដែលរដ្ឋបានធូស្រាលពវិបត្តិសេដ្ឋកិច្ចវិញគេក៏ចាប់រឹតបន្តឹងច្បាប់ឡើងវិញបណ្តាលឱ្យការងារចុះថយអ្នករកស៊ីតូចធំក្លាយជាសម្រាមក្មានប្រយោជន៍ត្រូវរដ្ឋស្រាវជ្រាវរកកំហុសញិចដូចចៃ ។ ករណីលោកស្រីម៉ាគ្គារេតម៉ាទិសជារឿងដែលទើបនឹងខុសច្បាប់ដែលកើតតាំងពីជាង១០ឆ្នាំមកហើយ ៕

**រៀបរៀងដោយវណ្ណាយីប**





# ហ្វេយ៍មីកខេប ផ្ទះសម្រាប់ពិធីបុណ្យសព
# Fay McCabe Funeral Home

105 Moore Street. Lowell, MA 01852
**978-459-9222**

**បម្រើសហគមន៍ខ្មែរដោយការយកចិត្តទុកដាក់ កិត្តិយស និងការគោរពជាង៣០ឆ្នាំមកហើយ**

- Serving All Faiths — បម្រើសេវាកម្មគ្រប់ជំនឿ
- Traditional Funerals — កម្មវិធីបុណ្យសពជាលក្ខណៈប្រពៃណី
- Cremation Services — មានផ្តល់សេវាបូជាសព
- Pre Arranged Funerals — រៀបចំរោងមុនកម្មវិធីបុណ្យសព



Locates 1 mile from Glory Buddhist Temple, between Gorham St. & Lawrence St.
ទីកន្លែងនៅចំងាយ១ម៉ាយពីវត្តពន្លឺពុទ្ធចក្ក ចន្លោះផ្លូវ Gorham St. & Lawrence St.

***លោកអ្នកនឹងក្រុមគ្រួសារទទួលបាននូវការយកចិត្តទុកដាក់ និងការបម្រើល្អប្រពៃពីទីនេះ ។***

www.faymccabe.com

**មានបុគ្គលិកនិយាយភាសាខ្មែរ**

Continued from Page 02

# 18th Middlesex Rep debate at...

the city of Lowell which would save rent costs for downtown location.

Question by Phil Geoffroy: Asks about state funding for higher education. What would you do to ensure adequate funding for institutions of higher education and to make sure it's affordable.

**Leary:** I've already done something on it with duel enrollment at Lowell High which lets students there get college credit. My daughter went to the state university of New York system. It was very affordable. Education is what we do in Massachusetts. We have to find a way to make public higher ed in Mass more affordable.

Mom: Education is a priority for all parents (I have 4). If I get elected, I will work with everyone to find resources to help people at all levels.

**Ouellette:** I'd work to keep state funding coming to Umass Lowell. We want everyone to have a quality education. But we have to be careful because if kids graduating from college have so much debt that they can't afford a house after graduation, it will cause our next housing glut.

**Yem:** I'll find ways to support low and middle class children especially in funding higher education. My daughter started college three days ago. We had to take out loans. I want to help graduates refinance their student loans to lower rates.


Chancellor Marty Meehan


Frank Talty

**Bahou:** I have two children in college. The cost is a burden. Other students tell me about having huge debt and trouble finding jobs. It's a crisis in America. Higher education is one of the most important things we have. Maybe the state's chapter 70 funding should be extended to higher ed students.

**Donovan:** Would support funding for state colleges. I would support increased grants for students going to state colleges.

Question by Chris Scott: What's the root cause of gun violence in the district and what would you do to curtail it.

**Mom:** Guns are not the issue. It's the education that we need to empower our youth and to teach our youth to respect life and one another. Lowell is a safe city. But when gunfire happens just up the street from my house there's something wrong with it. I know the police and the Superintendent are doing their best.

**Ouellette:** Courts need to follow through with laws already on the books. There's no fear and that doesn't deter people. Drug dealing is a root cause. I've seen the effect of drugs right here in my neighborhood. We have to teach kids that dealing drugs is not cool.

**Yem:** Drugs and mental health and a breakdown of family structures are root causes. I would toughen sentences for those who have illegal weapons. We should revisit Truth in Sentencing. Cites weaker gun laws in neighboring states.

**Bahou:** Guns are hurting our cities. People are afraid. I run a corner store and ask myself how many guns walk in here each week. Guns and gangs are the root cause. Guns are seen as "cool." Says the courts fail us by giving too many **Continued to Page 05**






Continued from Page 04

# 18th Middlesex Rep debate at...

chances to juvenile offenders.

**Donovan:** Cause of gun violence is the drug trade which is handled by gangs. We used to have a gang unit in the police department and a warrant unit that would look for these guys. We don't have those units anymore. If I was state rep, I'd find more funding to get more boots on the ground on the police department.

**Leary:** Root causes are drugs, breakdown of family and economic issues. Three pronged approach: educate young people with school resource



officers. Next is more boots on the street to do community policing. Biggest issues is how we appoint judges and how long they serve. We should have term limits for judges.

Soben Pin asks where should Lowell High School be located:

**Ouellette:** It needs to be researched. It doesn't belong at South Common because we need all the green space we have. Cawley Stadium would be the best spot if we moved I at all.

**Yem:** Cawley Stadium is the best location because it's close to highway and has athletic facilities. I haven't heard anyone ask the students what they think about the location of the high school. They should be part of the decision making process.

**Bahou:** There should be multiple conversations. Would it be feasible to have two high schools? I think the high school works in its current location because it's right between Umass Lowell and Middlesex Community College.

**Donovan:** I've heard $250mil to rehab the current facility. There's a study underway. There are a lot of students who walk to the current location. We should consider them. The students spend a lot of money downtown. For those reasons I'd prefer keeping it downtown.

**Leary:** I made the motion to begin this study. The school committee (and me) voted to keep it downtown but the state building authority will do its own study if they decide to help Lowell. You have to align this discussion with the needs of the city over the next couple of decades. I'm not wed to that; I'll listen to other suggestions but downtown seems best.

**Mom:** My first thought would be to create a brand new Lowell High but it's all about funding. This is where the pavement hits the road. If moving the high school would make downtown more vibrant, I'd be for it.

Question by Phil Geoffroy: What are the strengths and weaknesses of this year's state budget relative to this district? **Continued to Page 10**



Continued from Page 01

# Primary Election on...

running for Attorney General are **Maura Healey** and **Warren Tolman.**


២- ម៉ូរ៉ា ហេលី (Maura Healey)


១- វ៉ីរិន ថុលមែន Warren Tolman)

Secretary of State - in charge of state records, corporations, elections and securities. The current Secretary of State, **William Galvin,** is running unopposed for re-election.

State Auditor -inspects state financial records and procedures. The current State Auditor, **Suzanne Bump,** is running unopposed for re-election.


១- ស៊ូហ្សាម ប៊ុម Suzzanne Bump

Middlesex County District Attorney -the chief prosecutor for Middlesex County; supervises all lawyers who represent the state in criminal cases. The current District Attorney, **Marianne Ryan,** is running for re-election. She is being challenged by Michael Sullivan who is the current Middlesex County Clerk of Courts.


១- ដា ម៉ារៀន ធីរ៉ាយ៉ាន់ DA_Marian_T_Ryan

State Senate

-**Eileen Donoghue** - unopposed

State Representative -18th Middlesex District -The former state representative for this district, Kevin Murphy, became Lowell City Manager earlier this year. Candidates running for state representative are **Brian Donovan, Jim Leary, Rady Mom, Dave Ouellette and Paul RathaYem.**


១- អ៊ីលែន ដុងញី Eileen Donoghue

For the Republicans:

US Senate - Brian Herr

Congress - Ann Wofford

Governor - Charlie Baker or Mark Fisher

Lieutenant Governor - Karyn Polito


១-មីសឆែល ស៊ូលីវ៉ាន់ Michael Sullivan

Treasurer - Mike Heffernan

Attorney General - John Miller

Secretary of State - Dave D'Arcangelo

State Auditor -Patricia Saint Aubin

There are no Republican candidates in either the 1st Middlesex State Senate or the 18th Middlesex State Representative races.


WOFFORD_Ann


-MarkFisher


Brian Herr


Brian Herr










# The Cambodia daily

# ព្រះសង្ឃបណ្តេញសមាជិកសភាគណបក្សប្រជាជនចេញពីវត្ត

**ដោយៈម៉ិចដារ៉ា | September 4, 2014**

យោងតាមសាក្សីបានឱ្យដឹងថាសមាជិកសភាគណបក្សប្រជាជនកម្ពុជាម្នាក់មកពីខេត្តព្រះវិហារត្រូវបានបណ្តេញចេញពីវត្តមួយនៅរាជធានីភ្នំពេញកាលពីម្សិលមិញបន្ទាប់ពីបានធ្វើឱ្យអ្នកភូមិខឹងខ្លាំងដោយសារតែមិនបានបង្ហាញការយល់ស្របដល់ជម្លោះដីធ្លីរបស់ពួកគាត់។

កាលពីម្សិលមិញលោកសួសយ៉ារ៉ាសមាជិកសភាម្នាក់មកពីខេត្តព្រះវិហារបានធ្វើដំណើរទៅវត្តសាមគ្គីរង្សីដើម្បីជួបជាមួយប្រជាពលរដ្ឋ១៥៦គ្រួសារមកពីខេត្តនេះដែលបាននិងកំពុងធ្វើបាតុកម្មនៅរាជធានីភ្នំពេញដើម្បីអំពាវនាវដល់អាជ្ញាធរថ្នាក់ជាតិជួយធ្វើអន្តរាគមន៍ក្នុងជម្លោះរបស់ពួកគាត់អំពីដី៥៧០ហិកតា។

ព្រះតេជគុណថាច់ហាសំអាងចៅអធិការរងវត្តសាមគ្គីរង្សីបានមានសង្ឃដីកាថា ក្រៅតែពីមិនបានជួយលោកយ៉ារ៉ាបានត្រឹមតែធ្វើឱ្យអ្នកភូមិខឹងទៅវិញ។

ព្រះតេជគុណ ថាច់ ហា សំអាង បានមានសង្ឃដីកាថា "ហេតុអ្វីបានជាប្រជាពលរដ្ឋធ្វើដំណើរមករាជធានីភ្នំពេញដើម្បីតវ៉ាទាមទារដីរបស់ពួកគាត់"។

ព្រះតេជគុណមានសង្ឃដីកាថា "គាត់បានព្យាយាមឃាត់យើងមិនឱ្យមានសង្ឃដីកា...គាត់មកធ្វើឱ្យអ្នកភូមិខឹង។គាត់មិនបានមករកដំណោះស្រាយឱ្យអ្នកភូមិទេប៉ុន្តែគាត់មកគំរាមនិងបំភិតបំភ័យទៅវិញ"។

វីដេអូរយៈពេល៦នាទីដែលបង្ហោះលើបណ្តាញទំនាក់ទំនងសង្គមហ្វេសប៊ុកបានបង្ហាញការឆ្លងឆ្លើយបញ្ចេញកំហឹងដាក់គ្នារវាងលោកយ៉ារ៉ាព្រះសង្ឃ និងអ្នកភូមិ។

បន្ទាប់ពីការពិភាក្សាគ្នាប្រហែល២នាទីព្រះសង្ឃចាប់ផ្តើមស្រែកនិងចង្អុលលោកយ៉ារ៉ា។

លោកយ៉ារ៉ាបានតបវិញថា "ប្រសិនបើព្រះតេជគុណនៅតែបង្អាក់រំខានខ្ញុំតើខ្ញុំនិយាយយ៉ាងម៉េចកើត?"។

បន្ទាប់មកសមាជិកសភារូបនេះបានដើរសំដៅទៅរកច្រកចេញពីវត្តក្នុងពេលដែលព្រះសង្ឃជាច្រើនអង្គបន្តស្រែកដាក់។នៅទីបញ្ចប់លោកបានរត់ចេញទាំងបាតជើងសព្រាតពីអគារភ្លាមមួយរំពេចខណៈដែលព្រះសង្ឃនិងអ្នកភូមិមួយចំនួនតូចដេញតាមពីក្រោយ។

ប៉ុន្តែព្រះតេជគុណថាច់ហាសំអាងបានបដិសេធថាព្រះសង្ឃមិនបានដេញលោកយ៉ារ៉ាទេ។

ព្រះតេជគុណបានមានសង្ឃដីកាថា "យើងមិនបានដេញគាត់ចេញឬព្យាយាមវាយគាត់ទេប៉ុន្តែគាត់ខ្លាចហើយបានរត់ចេញដោយខ្លួនឯង"៕

**មានិត**






តមកពីទំព័រទី ០១

## ឡូវែលនឹងបោះឆ្នោតឱ្យខ្មែរ...

នេះឱ្យន័យថាមិនមែនតែខ្មែរ និងជនជាតិភាគតិចទេដែលចង់បានឱ្យបេក្ខជនខ្មែរម្នាក់នេះជាប់ឆ្នោតទោះបីសហគមន៍ស្បែកសក៏បង្ហាញការគាំទ្រដល់បេក្ខជនមួយនេះដែរ ។ បង្ហាញសមត្ថភាពបេក្ខជនច្រើនដងមកមនុស្សប្រសើរនោះបានលេចមកមែនក្នុងទស្សនៈម្ចាស់ឆ្នោត ។ ឡូវែលនឹងបោះឆ្នោតឱ្យខ្មែរពីព្រោះទាំងខ្មែរទាំងសាសន៍ដ៏ទៃចង់ឃើញខ្មែរក្លាយជាតំណាងរដ្ឋនៃសង្កាត់ដែលមានខ្មែរច្រើនរស់នៅ ប៉ុន្តែលោកអ្នកបោះឆ្នោតឱ្យបានតែម្នាក់ទេដូច្នេះឆ្នោតដ៏មានតម្លៃរបស់លោកអ្នកត្រូវតែប្រមង់ឱ្យចំកន្លែងដែលប្រមូលប្តុំឆ្នោតខ្មែរនឹងបរទេសរួមគ្នាធ្វើដូចនេះទើបសម្រេចបំណងចម្បងរបស់លោកអ្នកបានគឺការរៀបចំអនាគតឱ្យរីតតែប្រសើរឡើង ៕

*"ទៅបោះឆ្នោតដោយដឹងច្បាស់ថាខ្លួនកំពុងធ្វើអ្វីគឺមានន័យបំផុតសម្រាប់ជីវិតនឹងសម្រាប់គ្រួសារខ្លួន"*



Rady Mom

បើសន្លឹកឆ្នោតប្រមូលផ្តុំទៅលើនរណាម្នាក់ហើយនឹងបានន័យថានរនោះនឹងមានឋាមពលច្រើនសម្រាប់បំរើសហគមន៍វិញសហគមន៍ខ្មែរខ្លួនឯងក៏មានការគាំទ្រពីសង្គមរដ្ឋបាលច្រើនមកវិញដែរ ។ ប្រសិនបើសន្លឹកឆ្នោតគាំទ្រដល់បេក្ខជនដែលខ្លួនពេញចិត្តបែរជាបានតិចតួចទៅវិញនោះទាំងបេក្ខជនទាំងសហគមន៍នឹងនៅតែទន់ខ្សោយត្រូវគេមើលងាយដូចមុនដដែលដូច្នេះវាជាការសមរម្យនឹងទទួលផលនេះហើយដោយសារតែយើងមើលងាយការងាររបស់ខ្លួនឯងទៅហើយដោយមិនទៅបោះឆ្នោត ឬបោះឆ្នោតមិនត្រឹមត្រូវឱ្យខូចសន្លឹកឆ្នោត ។

**បោះឆ្នោតប្តូរសង្គមៈ** យុវនារីម្នាក់បាននិយាយថា "ខ្ញុំចង់ឃើញខ្មែរម្នាក់ឈ្នះឆ្នោតដោយស្មើមុខអាមេរិកាំងមិនមែនដោយសារតែយើងគ្រាន់តែជាខ្មែរប៉ុណ្ណោះទេ" គឺជាការប្តូរចរន្តទស្សនៈដ៏ធំមួយនៅឡូវែលនេះដែលម្នាក់ៗរង់ចាំ "ការឈ្នះឆ្នោតដោយគិតត្រូវមិនមែនដោយសារតែភឿន" –"ភាពរុងរឿងដោយសារសុច្ចរិតមិនមែនដោយសារកេងប្រវ័ញ្ច"... ។ អ្នកជាប់ឆ្នោតលើកនេះមានឱកាសជាអ្នកឈ្នះស្មើមុខនឹងអាមេរិកាំងដូច្នេះនឹងមានកម្លាំងគ្រប់គ្រាន់សម្រាប់ប្តូរនឹងលើកដំកើងសង្គមដែលខ្លួនឯងសច្ចាថានឹងការពារបាន ។ ពេលនេះសង្គមខ្មែរត្រូវការតំណាងជាខ្មែរម្នាក់ដែលដឹងពីជំរៅចិត្តខ្មែរត្រូវការក្រោកឈរចេញពីភាពក្រីក្រនឹងត្រូវការកិត្តិយសមកវិញ ។

ឡូវែលនឹងបោះឆ្នោតៈយើងមិនចូលចិត្តលើកដំកើង"ខ្មែរត្រូវបោះឆ្នោតឱ្យខ្មែរ"ទេតែលើកដំកើង"ខ្មែរបោះឆ្នោតឱ្យអ្នកប្រសើរ" ឥឡូវនេះបន្ទាប់ពី



# វិស្សមកាលចុងរដូវក្តៅនៅរ៉ូដអាឡិន

**ដោយ :ពិន សំខុន**

ធ្វើកាសែតចប់លេខ១៦០ យើងបង្ខំចិត្តបង្ហើយការណ៍ផ្សេងៗទៀតឱ្យបានលឿន ដើម្បីឱ្យឆាប់បានសម្រាកហើយយកពេលមួយថ្ងៃទៀតសម្រាប់ដើរចែកកាសែតដែល ទើបបោះពុម្ពរួចទៅទម្លាក់នៅតាមហាងលក់ឥវ៉ាន់តូចធំនៅឡូវែលនៅលីនរីវែរបន្ទាប់មកយកកាសែតមួយចំនួនទៅផ្ញើរតាមឡានគ្រេហោនទៅចែកចាយដល់ហាងខ្មែរនៅហ្វីឡាដែលហ្វៀទៀតបន្ទាប់មកទៀតយើងប្រញាប់រេចឥវ៉ាន់ចាំបាច់សម្រាប់ចេញដំណើរទៅវិស្សមកាល៥ថ្ងៃទៅរ៉ូដអាយឡិន។ នា២ខែចុងក្រោយនេះ យើងបានធ្វើការយ៉ាងហត់នឿយប្រើពេលយ៉ាងច្រើនសម្រាប់គិតនឹងបំពេញការងារប្រើវាមពលដើម្បីជម្រុញការគិតឱ្យទៅដល់គោលដៅនៅសល់ការងារខ្លះទៀតដែលត្រូវតែបង្ហើយបន្សល់ដោយបុគ្គលិកដែលធ្វើការងាររបស់ខ្លួនមិនទាន់យើងនឹងរីករាយណាស់ បើបញ្ចប់ការងាររបស់យើងបាននៅថ្ងៃនេះ ទោះជាឃើតពេលយ៉ាងណាក៏ដោយ។ ចុងបញ្ចប់នាល្ងាចថ្ងៃសុក្រម៉ោង៦កន្លះ ទើបបញ្ចប់ការងារចុងក្រោយទាំងអស់បាន ហើយរហូតដល់ម៉ោង៩យប់ ទើបគ្រួសារយើងផ្តើមចេញដំណើរទាំងយប់សំដៅទៅកាន់រដ្ឋរ៉ូដអាយឡិននាទីក្រុងប្រូវីដិនដែលនៅចម្ងាយប្រមាណ១ម៉ោង១៥នាទីបុណ្ណោះពីក្រុងឡូវែល។


ដេញ៉ុល,អេដែន,សារ៉ាន់,សុបិន្ត,សំខុន


បន្លែបានមកពីសួនច្បារ

**ទៅលេងប្រូវីដិនតំបន់ខ្មែររស់នៅច្រើនៈ**

ការពិតទៅម្តុំប្រូវីដិនមានរមនីយដ្ឋានជាច្រើនដែលគេអាចទៅទស្សនាកំសាន្តបានយើងបានទៅកាត់ដំបន់នេះច្រើនដងហើយដែរតែមិនដែលមាននរណាមកចង្អុលបង្ហាញថា នៅទីនោះមាន


ហាន់លី,សារ៉ាន់,អេដែន,ដាញែល

ដំបន់គួរឱ្យចង់ទៅទស្សនាម្តងណាទេទើបតែលើកនេះយើងមានពេលសម្រាកក៏តិចមិនអាចទៅទីឆ្ងាយបានក៏សម្រេចទៅវិស្សមកាលទីជិតៗទៅវិញនោះ។

យើងបានទៅសំណាក់ផ្ទះគ្រួសារមួយជាមិត្តភក្តិគឺអ្នកស្រីសារ៉ាន់ជាខ្មែរនឹងលោកដានិញលជនជាតិអ៊ីតាលីនៅប្រូវីដិននោះ។ អ្នកទាំងពីរបានចងជាគ្រួសារចំនួន២៧ឆ្នាំហើយ មានកូនប្រុសពីរនាក់ធំៗអស់ ហើយម្នាក់ចូលធ្វើទាហ៊ាននៅញូយ៉កតែអកុសលបានទទួលគ្រោះថ្នាក់ដល់

តទៅទំព័រទី ១១

Elect

Jim Leary

State Representative

18th Middlesex District

My name is Jim Leary. For the past 8 years I've been fortunate to represent you on the Lowell School Committee. I am now asking for the opportunity to represent you on Beacon Hill as your State Representative. I will fight for economic development, high quality schools and keeping Lowell safe.

ខ្ញុំឈ្មោះ ជីម លើរី អស់រយៈពេល៨ឆ្នាំមកហើយដែល ខ្ញុំមានសំណាង និងបានជាតំណាងលោកអ្នកនៅគណៈកម្មការ សាលារៀនឡូវែល ។

នាពេលនេះទៀត ខ្ញុំសុំឱ្យលោកអ្នកផ្តល់ឱកាសឱ្យខ្ញុំអាចក្លាយជាតំណាងលោកអ្នកនៅប៊ីខិន ហៀល ជាតំណាងរដ្ឋរបស់លោកអ្នក ។ ខ្ញុំនឹងខិតខំប្រយុទ្ធដើម្បីអភិវឌ្ឍន៍ សេដ្ឋកិច្ច គុណភាពខ្ពស់របស់សាលារៀន ហើយរក្សាឡូវែលឱ្យមានសន្តិសុខ ។



On September 9th, I respectfully ask for your vote.

Continued from Page 05

# 18th Middlesex Rep debate at...

**Yem:** I haven't seen much in this budget that helps the 18th Middlesex District. I'd try to add amendments that provided for capital improvements in the district in the coming years. Also more grant funding for students pursuing higher education.

**Bahou:** There should be more funding about drugs and drug education. Also about guns. Lottery funding should be used more for Lowell. The formula is unfair.

**Donovan:** Money came to Lowell this year to support our public schools. This is the most important part of state aid to Lowell. For us to improve our economy, we need a first rate school system. I would advocate for more funding for public schools and for Umass Lowell.

**Leary:** I'd like to see a two or three year budget so we know for a longer time what our funding will be. Now, it's too unpredictable from year to year. Lowell pays $8mil in out of district special ed costs. The people getting those services need them but they shouldn't come directly from the city's school budget

**UPDATE**

**Mom:** He would talk with everyone about it. Stresses that he would be a bridge between the Cambodian community and the rest of the city.

**Ouellette:** Would find funding for a new sprinkler installation plan he has that would allow landlords to install sprinklers for an affordable price. He cites a lead removal program that give building owner a grant that he repays when the building is sold. This will put all kinds of people to work and will make the housing safer.

**CLOSING STATEMENTS**

**Bahou:** Unenrolled candidate will be on ballot in November. My parents came here as immigrants in 1957. Was born in "this building" in 1953. Cites involvement in youth activities. Has invested in many properties in this district. He owns his own corner store and is accessible to the community. I understand the interests of small business. We have to follow through with our support of them.

**Donovan:** Thanks Umass Lowell, the students, and the voters of the district. He will represent them full time. Will work to reduce violence, improve schools, will get increased funding especially for economic development projects.

**Leary:** Thanks everyone. I've been on school committee for 8 years, a devastating time for school funding. Took a lot of tough votes but helped rebuild the school system. I want to connect Cambodia Town with downtown. Umass Lowell is rehabbing part of Lowell. I'd like to be part of that and align Umass Lowell's objectives with those of the city. We've done that with the school system. Education leads you to economic prosperity.

Lowell will be a college town but we need a thriving downtown and thriving minidowntowns in each neighborhood.

Mom: I came to this country at age 12, not speaking a word of English. I own and run a therapy business in Cupples Square. My wife and I are raising 4 children here in Lowell. I'm a product of Lowell public schools. Lowell has a great heritage. I want to make sure Lowell is a city where people feel secure. I've met many people and have listened to their concerns. Talks about the significance of being first Cambodian representative in Massachusetts. Pledges to work together with everyone.



University Crossing at night



ភ្ញៀវមកស្តាប់កិច្ចពិភាក្សា

Ouellette: Thanks everyone. Asks for our vote. Grew up in public housing here in the Acre. Has been married for 32 years living on Cabot Street. Got involved with neighborhood when gunfire erupted outside his house one night. Cites meeting with former police chief who asked someone to be the strong voice for the neighborhood. He's tried to fill that role. Cites work on North Common, working with UTEC, Habitat for Humanity. I've been there and I will still be here. This is what I've been doing and this is what I'll continue doing.

Yem: Explains process of voting with stickers (since he's not on the ballot). He's married with children and lives in the Acre. Is a real estate broker with an office in CupplesSqu are. Is secretary of Cambodia town. Humbly asks for our votes. Says if he's elected, it won't be business as usual.






តមកពីទំព័រទី ០៩
## វិស្សកាលចុងរដូវក្តៅនៅរ៉ូដអាយឡិន...

ជីវិតកាលពីឆ្នាំទៅនេះ រីឯកូនប្រុសម្នាក់ទៀតមានគ្រួសារក៏បានបែកចេញពីឪពុកម្តាយទៅរស់នៅដោយខ្លួនឯងថែមទៀតធ្វើឱ្យផ្ទះស្វាមីភរិយាកំសត់កំរមួយគូរនេះក្លាយជាស្ងាត់ជ្រងុំនាប៉ុន្មានឆ្នាំចុងក្រោយនេះ ។ ផ្ទះស្ងាត់មែនតែមានការតុបតែងស្អាតបាតជាផ្ទះបែបអឺរ៉ុបជុំវិញផ្ទះមានសួនច្បារលំអដោយផ្កាចំរុះពណ៌មានច្បារដំណាំឱ្យផ្លែធំធាត់ជាច្រើនរងផង។ អ្នកស្រី សាវ៉ាន់រួសរាយនឹងឧស្សាហ៍ក្នុងការថែរផ្ទះនឹងសួនច្បារឱ្យមានសោភ័ណ្ឌភាពត្រកាលជានិច្ច ។ នៅទីនោះយើងបានដឹងថាតំបន់ប្រូវីដិននៃរដ្ឋរ៉ូដអាយឡិនជាតំបន់ដែលជាជម្រកនៃសហគមន៏អ៊ីតាលិយានដ៏ច្រើនកាលពីអតីតកាលដែលបានមកតាំងទីប្រកបដោយជីវភាពជោគជ័យ ឥឡូវមួយចំនួនធំនោះក៏បានបែកខ្ញែកគ្នាទៅរស់នៅទីផ្សេងៗគ្នាជាបន្តរបន្ទាប់ដោយសារតែវិបត្តសេដ្ឋកិច្ចនៃសហរដ្ឋអាមេរិកតែក៏នៅសល់អាមេរិកាំងដើមកំណើតអ៊ីតាលីច្រើននៅឡើយនៅប្រូវីដិននេះដែរ ។

នាប្រមាណជា៣0ឆ្នាំចុងក្រោយនេះចរន្តនៃជនភៀសខ្លួនបាននាំបងប្អូនខ្មែរមករស់នៅតំបន់ប្រូវីដិនកាន់តែច្រើនកកកុញជាពិសេសម្តុំសង្កាត់ក្រេងស្តុន Cranston nwgv:vIk Warwick ដែលគេអាចសំគាល់ដោយផ្ទះសម្បែងខ្មែរបេកហាងលក់ដូរធំតូចដូចជាភោជនីយដ្ឋានមានហាងគុយទាវហាងចាប់ហួយធំៗ បី-បួនកន្លែងហាងលក់វីដេអូហាងលក់មាសកន្លែងជួសជុលរថយន្ត





គ្រប់ធុនមានវត្តអារាមធំៗមានទាំងសមាគមខ្មែរផង ។ យើងដឹងថា មានស្ថិតិបានឱ្យចំនួនពលរដ្ឋដើមកំណើតខ្មែរប្រមាណ៧ពាន់នាក់ តែបើយោងតាមទំហុំនៃកន្លែងធ្វើពាណិជ្ជកម្មកន្លែងប្រជុំជនខ្មែរ ។ល។ ចំនួននោះអាចនឹងមិនតិចជា១ម៉ឺននាក់ទេ នៅដំបន់ប្រូវីដិននោះ ។ កាសែតខ្មែរផុស ស.រ.អា. មានវត្តមាននៅតំប់ន់ប្រូវីដឹននោះប្រមាណ៥ឆ្នាំហើយដែរផ្សព្វផ្សាយដំណឹងពីសហគមន៏ខ្មែររឿងរាល់២សប្តាហ៏ម្តង ដោយចែកផ្សាយម្តងៗចំនួន១ពាន់សន្លឹកនៅប្រូវីដិននោះ។ ប្រជាពលរដ្ឋខ្មែរកាន់តែច្រើនចូលចិត្តអានកាសែតខ្មែរដែលនិយាយពីសហគមន៏ខ្លួនឯងពីព្រោះគាត់

មិនពូកែរអានកាសែត ឬមើលទូទស្សន៏ភាសាអង់គ្លេសទេតែក៏មិនចូលចិត្តឱ្យគេនិយាយពីរឿងអាស្រូវរបស់សហគមន៏ខ្មែរដែរចូលចិត្តលាក់ការណ៏យ៉ាងស្ងប់ស្ងៀមក្រែងបានមុខមាត់ប្រសើរ ឬថា បានសុខជាង។ ខ្មែរនៅប្រូវីដិនមានស្ថានភាពរស់នៅនឹងទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងតំបន់ជិតខាងដែលមានខ្មែរច្រើនរស់នៅដូចគ្នាដូចជាអ្នករស់នៅ"កូណិចទីកិទ" ឬនៅញូយ៉កដែរ តែអ្នកនៅខាងញូយ៉កឬក៏នៅជាប់ខាងជើងញូយ៉កគេសម្បូរកាងារធ្វើច្រើនជាង ដូច្នេះមានជីវភាពប្រសើរជាងអ្នកនៅតំបន់ដ៏ទៃ។

ប្រូវីដិនថ្វីត្បិតតែមានខ្មែរច្រើនគួរសមតែមិនមានអ្នកប្រជែងគ្នាឈរឈ្មោះជាអ្នកនយោបាយអាមេរិកាំងទេតែជិតជាប់អាណិតអាសូរទៅនឹងវាសនារបស់កម្ពុជាច្រើនជាងនាំគ្នាប្រមូលលុយកាក់មានបន្តិចបន្តួចទៅជួយស្រុកខ្មែរបារអសៈពីហោប៉ាវ រីឯអ្នកនយោបាយវិញ ក៏តែងតែចូលកាត់តំបន់នោះដើម្បីអរគុណម្ចាស់អំណោយដែរ ។

នៅកណ្តាលក្រុងដែលខ្មែររស់នៅច្រើននោះមានរមនីដ្ឋានសួនសត្វដ៏ធំសម្បើមមួយដែលជាទីចំណូលចិត្តរបស់កុមារនឹងអ្នកចូលចិត្តចង់ចេះដឹងពីសត្វព្រៃ។ លេខក្រោយយើងនឹងបន្តបីពណ៌នាបីសួនសត្វនៅប្រូវីដិនជូនជាសណ្តាប់ជាបន្តទៅទៀត ៕







ឌឺ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឺ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ សុក្រ ទី០៥ ខែកញ្ញា ឆ្នាំ២០១៤

# អតីតនាយករដ្ឋមន្ត្រីគាំទ្រការកំណត់អាណត្តិនាយករដ្ឋមន្ត្រី

**ដោយ : ឃី សុវុឌ្ឍី | September 4, 2014**

នៅក្នុងកិច្ចប្រជុំដំបូងក្នុងចំណោមកិច្ចប្រជុំមួយចំនួនជាមួយអតីតនាយករដ្ឋមន្ត្រីសម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត(ERA)បានជួបជាមួយលោក ប៉ែន សុវណ្ណ នៅក្នុងរដ្ឋសភាដើម្បីពិភាក្សាអំពីសំណើកំណត់អាណត្តិនាយករដ្ឋមន្ត្រីកាលពីម្សិលមិញ។

សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោតជាសម្ព័ន្ធនៃអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកដែលត្រូវបានបង្កើតឡើងបន្ទាប់ពីការបោះឆ្នោតជាតិដ៏ចម្រូងចម្រាសកាលពីឆ្នាំមុនបានស្នើឱ្យមានការកំណត់អាណត្តិនាយករដ្ឋមន្ត្រីអំឡុងកិច្ចប្រជុំមួយក្នុងចំណោមកិច្ចប្រជុំតុមូលមួយចំនួនដែលធ្វើឡើងតាមធម្មតាក្នុងរាជធានីភ្នំពេញកាលពីខែមុន ហើយបានទទួលការគាំទ្រពីសំណាក់អ្នកនយោបាយលេចធ្លោមួយចំនួនចាប់តាំងពីពេលនោះមក។

លោក ប៉ែន សុវណ្ណ ដែលកាលពីឆ្នាំ១៩៨១ បានធ្វើជានាយករដ្ឋមន្ត្រីដំបូងនៃប្រទេសកម្ពុជាមួយរយៈបន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ ត្រូវបានជ្រើសរើសឱ្យធ្វើជាសមាជិកសភារបស់គណបក្សសង្គ្រោះជាតិកាលពីឆ្នាំមុន។ លោកបានធ្វើជាអ្នករៀបចំកិច្ចប្រជុំសម្រាប់សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោតកាលពីព្រឹកម្សិលមិញនៅការិយាល័យថ្មីរបស់លោកក្នុងអគាររដ្ឋសភា។

លោក ប៉ែន សុវណ្ណ បានប្រាប់អ្នកយកព័ត៌មានបន្ទាប់ពីកិច្ចប្រជុំថា "ខ្ញុំគាំទ្រគំនិតនេះ ហើយខ្ញុំចង់ឱ្យមានការកំណត់អាណត្តិនាយករដ្ឋមន្ត្រីចន្លោះពីមួយអាណត្តិ និងដល់រយៈពេល១០ឆ្នាំ"។ អាណត្តិនាយករដ្ឋមន្ត្រីគឺរយៈពេល៥ឆ្នាំ។

លោក ប៉ែន សុវណ្ណ បានមានប្រសាសន៍បន្តថា "នៅពេលនរណាម្នាក់ធ្វើជានាយករដ្ឋមន្ត្រីយូរអង្វែងវាបណ្តាលឱ្យមានគំនិតផ្តាច់ការគ្រួសារនិយមមិត្តភក្តិនិយម និងបក្សពួកនិយម"។

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានដឹកនាំរដ្ឋាភិបាលអស់រយៈពេល២៩ឆ្នាំមកហើយដោយទទួលបានជ័យជម្នះលើលោក ចាន់ ស៊ី ដែលជំនួស

**តទៅទំព័រទី ២៣**

# Ex-Prime Minister Makes Case for Term Limits

**By Khy Sovuthy | September 4, 2014**

In the first of an apparent series of meetings with former prime ministers, the Electoral Reform Alliance (ERA) on Wednesday met with Pen Sovann at the National Assembly to discuss their proposal to impose term limits on prime minister.

The ERA, a coalition of local NGOs established after last year's disputed national election, proposed term limits during one of their regular roundtable meetings in Phnom Penh last month and have since won the support of a number of high-profile politicians.

Mr. Sovann, who in 1981 served briefly as the first prime minister of Cambodia after the fall of the Khmer Rouge, was elected as an opposition CNRP lawmaker last year. He hosted the ERA on Wednesday morning at his new office in the National Assembly building.

"I support this idea and I want a limit on the prime minister's term from between one mandate and 10 years," Mr. Sovann told reporters following the meeting.

A parliamentary mandate is five years.

"If one has been prime minister for too long, it causes the regime to be defective and him [the prime minister] to be nepotistic and [to show] favoritism and partisanship," Mr. Sovann said.

Prime Minister Hun Sen has served as head of government for 29 years, having succeeded Chan Sy, who replaced Mr. Sovann when he was purged by the Vietnamese-backed regime in December 1981 and sent to prison for a decade in Hanoi.

"I think that when one holds the position of prime minister for more than 10 years, he [develops] defective ideas," Mr. Sovann said.

"He thinks that he is the best person,

**Continued to Page 23**

# US-Cambodian Businessman Jailed in $1M Fraud Case

**BY SIMON HENDERSON AND HAY PISEY | SEPTEMBER 4, 2014**

Prominent Cambodian-American businessman Richer San was arrested Wednesday morning in Phnom Penh's Daun Penh district and sent to PJ Prison for his alleged role in defrauding dentist Eng Lykuong of $1 million, officials said.

On August 21, the Phnom Penh Municipal Court issued an arrest warrant for Mr. San, who was summoned for questioning a month earlier along with three other well-connected businessmen—Sichan Siv, formerly a U.S. ambassador to the U.N. and author of the renowned Khmer Rouge survival memoir "Golden Bones"; New York State Assemblyman William Nojay and Thomas Willems, a former director of the NGO Cambodia International Education Support Foundation-USA.

The arrest of Mr. San follows a complaint filed with the court by Ms. Lykuong, who claims the men conned her into investing $1 million in their company, Akra Agricultural Partners, by peddling a number of phony business deals.

"Mr. San Richer was arrested over accusations of fraud on Wednesday morning in front of Chaktomuk police office in Daun Penh district's Chaktomuk commune while he was driving a car accompanied by his wife," said Sar Piseth, deputy chief of the municipal police's warrant execution bureau, who made the arrest.

Mr. San and his wife, Sithea San—a power couple in the Cambodian-American community—founded the business hub Cambodia Town in Long Beach, California, but have lived in Phnom Penh since 2012.

Outside the courtroom Wednesday, Mr. San's wife declined to comment on her husband's role in the case but said he was cooperating with the court.

"We are good people and we are honest people and we will do things right," she said.

When Mr. San emerged from the investigating judge's office just before 6 p.m., he denied the charge against him and said he trusted the court to clear his name.

"Innocent until proven guilty," he said.

"She [Ms. Lykuong] is the one who should be answering questions…but I still believe in the Cambodian justice system."

Mr. San said he had had no recent contact with the co-accused.

"I am the one who is here, I don't know about them. I am very disappointed—I have given so much to the country of my birth," he said before being hurried into a police Land Cruiser and driven to the minimum-security PJ Prison.

Ms. Lykuong said Wednesday that Mr. San's role in the alleged fraud was now for the court to determine.

"He can continue denying the allegation but I will leave it up to the court to decide and find me justice," Ms. Lykuong said in an email.

She said despite Mr. San's arrest, she remained distressed, as the other three defendants have yet to be brought to court.

"My justice has not been fully served yet. The case is very complex and painful for me," she said.

Ms. Lykuong's lawyer, Orn Hing, said Wednesday that of the four summoned for questioning, only Mr. San was present in Cambodia.

"Mr. Thomas Willems went to Thailand and Mr. Sichan Siv has gone to the USA," he said.

Mr. Nojay resides in New York.

Mr. Hing said that Mr. San was arrested Wednesday after filing a complaint with the Appeal Court, following his receipt of an initial summons by the Phnom Penh court, challenging its stipulation that he must remain in Cambodia.

"The Phnom Penh Municipal court issued a summons, but Mr. San did not go to the court—that is why he was arrested by the municipal police, in case he might escape going to court," he said.

Investigating Judge Oeung Sieng could not be reached.

Mr. Siv and Mr. Nojay have not responded to multiple requests for comment. Mr. Willems also could not be reached.

**henderson@cambodiadaily.com, pisey@cambodiadaily.com**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសំរួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ សុក្រ ទី០៥ ខែកញ្ញា ឆ្នាំ២០១៤

# តុលាការចោទប្រកាន់បុរសវៀតណាម៧នាក់ដែលវាយយុវជនខ្មែរ

**ដោយ អ៊ូច សូនី | SEPTEMBER 4, 2014**

ក្រុមមន្ត្រីបាននិយាយថា កាលពីម្សិលមិញ សាលាដំបូងរាជធានីភ្នំពេញ បានចោទប្រកាន់បុរសវៀតណាម៧នាក់ពីបទប្រព្រឹត្តអំពើហិង្សាដោយចេតនា វាយប្រហារយុវជនមួយក្រុមកាលពីល្ងាចថ្ងៃសៅរ៍ នៅខណ្ឌច្បារអំពៅ បណ្តាលឱ្យយុវជនអាយុ១៩ឆ្នាំម្នាក់ដាច់របេះត្រូវដេរជាង៣០ថ្នេរ ។

ហេតុការណ៍នៅសង្កាត់ព្រែកប្រាបានបង្កឱ្យមានការតវ៉ាជាខ្លាំងកាលពីថ្ងៃច័ន្ទ ពេលដែលជនរងគ្រោះ កែវ សុធារ៉ា ត្រូវបាននគរបាលឃាត់ខ្លួនមួយយប់ បើទោះជារងរបួសធ្ងន់ដោយសារអំបែងដប ជាការវាយប្រហារមិនដឹងមូលហេតុលើក្រុមយុវជនដែលកំពុងលេងបាល់ទាត់ក៏ដោយ ។

លោក ម៉ី ចរិយា ប្រធានគនរបាលព្រហ្មទណ្ឌខណ្ឌ ដែលបានចាប់ខ្លួនបុរសទាំងនោះនៅផ្ទះជួលរបស់ពួកគេនៅក្បែរកន្លែងកើតហេតុនោះ បានមានប្រសាសន៍ថា តុលាការបានចោទបុរសទាំង៧នាក់កាលពីរសៀលម្សិលមិញ ប៉ុន្តែលោកមិនបានដឹងឈ្មោះចៅក្រមស៊ើបអង្កេតដែលទទួលបន្ទុករឿងក្តីនេះទេ ។

លោកបានមានប្រសាសន៍ថា "គេបានបញ្ជូនជនសង្ស័យទៅពន្ធធនាគារព្រៃសហើយឥឡូវនេះដើម្បីឃុំខ្លួនរង់ចាំការកាត់ក្តី" ។

លោកស្រី វ៉ា សក្ដា ព្រះរាជអាជ្ញារងសាលាដំបូងរាជធានីភ្នំពេញបានបញ្ជាក់ថា លោកស្រីបានសាកសួរបុរសទាំងនោះនៅតុលាការ និងបានបញ្ជូនសំណុំរឿងនេះទៅចៅក្រមស៊ើបអង្កេត ប៉ុន្តែមិនមានព័ត៌មានបន្ថែមទៀតទេ ។

លោកស្រីបានមានប្រសាសន៍ថា "ខ្ញុំមិនដឹងថាចៅក្រមណាកាន់សំណុំរឿងនេះទេ ឬជនទាំងនោះជាប់ចោទពីបទអ្វីឡើយ" ។

អ្នកស្រី គង់ សុភី ម្តាយជនរងគ្រោះបានប្តឹងកាលពីថ្ងៃអង្គារទាមទារសំណងដោយសារការរងរបួសជាទម្ងន់នៅខ្នងផ្នែកខាងលើ និងទុក្ខព្រួយផ្លូវចិត្តជាខ្លាំង ។

ដោយសំដៅដល់សេចក្តីសម្រេចរបស់តុលាការក្នុងការធ្វើការចោទប្រកាន់បុរសទាំងនោះ អ្នកស្រីបានមានប្រសាសន៍ថា "ខ្ញុំរីករាយណាស់ដែលបានឮព័ត៌មាននេះ ហើយខ្ញុំសង្ឃឹមថា កូនប្រុសរបស់ខ្ញុំនឹងទទួលបានយុត្តិធម៌ជាមិនខាន" ។

ទោះជាយ៉ាងនេះក្តី លោកបានបន្ថែមថា អ្នកស្រីព្រួយបារម្ភថា ខ្លាចនៅទីបញ្ចប់តុលាការនឹងសម្រេចអនុគ្រោះដល់បុរសវៀតណាមទាំងនោះ ។

លោក នី ចរិយា អ្នកស៊ើបអង្កេតជាន់ខ្ពស់នៃសមាគមការពារសិទ្ធិមនុស្សអាដហុកដែលមេធាវីរបស់អង្គការលោកតំណាងឱ្យជនរងគ្រោះ បានស្វាគមន៍សេចក្តីសម្រេចរបស់តុលាការ ប៉ុន្តែបានសំដែងកង្វល់ថា ការចោទពីបទអំពើហិង្សាដោយចេតនាគឺជាទោសស្រាលពេកហើយ ។

លោកបានមានប្រសាសន៍ថា "ខ្ញុំស្វាគមន៍បទចោទនេះ ប៉ុន្តែវាហាក់ដូចជាស្រាលពេកជនរងគ្រោះអាចដាច់កដោយងាយ ហើយអាចស្លាប់ទៀតផង" ។ លោកបានបន្ថែមថា ក្រុមមេធាវីរបស់អង្គការអាដហុកកំពុងប្រមូលភ័ស្តុតាងថែមទៀតក្នុងរឿងក្តីនេះ ។

លោកបានមានប្រសាសន៍ថា "ប្រសិនបើយើងពិនិត្យមើលហេតុការណ៍ដែលបានកើតឡើងពិតប្រាកដ គឺមនុស្ស៧នាក់វាយមនុស្សម្នាក់បទចោទគួរតែជាបទចោទប៉ុនប៉ងធ្វើមនុស្សឃាត" ៕

**មានិត**

# Court Charges Vietnamese Men After Attack

**BY OUCH SONY | SEPTEMBER 4, 2014**

The Phnom Penh Municipal Court on Wednesday charged seven Vietnamese men with intentional violence after an attack on a group of youths on Sunday evening in Chbar Ampov district left a 19-year-old man with gash requiring more than 30 stitches, officials said.

The incident in Prek Pra commune provoked an angry protest on Monday when the victim, Keo Sotheara, was detained overnight by police despite suffering a serious wound inflicted by a broken bottle in what witnesses said was an unprovoked attack on youths playing football.

District penal police chief Mey Chakriya, who arrested the men at their rental house close to where the incident occurred, said the court charged the seven men Wednesday afternoon, though he did not know the name of the investigating judge in charge of the case.

"They have been sent to Prey Sar prison now for pretrial detention," he said.

Deputy municipal court prosecutor Va Sakada confirmed that she questioned the men at the court and sent the case to the investigating judge but did not have further information.

"I don't know which judge is handling this case or what the men were charged with," she said.

The victim's mother, Kong Sophy, filed a complaint on Tuesday demanding compensation due to the seriousness of the wound to his upper back and emotional distress.

"I am very happy to hear the news and I hope my son will get justice," she said, referring to the court's decision to charge the men. He added, however, that she worried that the court would eventually rule in favor of the Vietnamese men.

Ny Chakriya, senior investigator for local rights group Adhoc, whose lawyers are representing the victim, welcomed the court's decision but expressed concern that the charge of intentional violence was overly lenient.

"I welcome the charge but it seems too light—the victim could easily have had his neck cut and could have died," he said, adding that Adhoc's lawyers were gathering more evidence in the case.

"If we look at what really happened—seven people attacked one person—the charge should have been one of attempted killing," he said.

# រដ្ឋាភិបាលមានគម្រោងហាមប្រាមការប្រើប្រាស់ពាក្យពេចន៍អសីលធម៌តាមប្រព័ន្ធអ៊ីនធើណិត

**ដោយ៖ ហ៊ុល រស្មី | SEPTEMBER 4, 2014**

យោងតាមមន្ត្រីក្រសួងព័ត៌មានម្នាក់បានឱ្យដឹងថា ក្រសួងព័ត៌មានមានគម្រោងចាប់ផ្តើមធ្វើនិយតកម្មប្រព័ន្ធអ៊ីនធើណិតទាំងអស់នៅក្នុងប្រទេសកម្ពុជា ដើម្បីទប់ស្កាត់ការប្រើពាក្យពេចន៍វាយប្រហារមិនឱ្យចុះផ្សាយតាមប្រព័ន្ធអ៊ីនធើណិត ដើម្បីទប់ស្កាត់ការបរិហារកេរ្តិ៍ និងការបង្កអំពើហិង្សាជាដើម ។

លោក អ៊ុក គីមសេង ទីប្រឹក្សាក្រសួង និងជាអ្នកផ្តួចផ្តើមគំនិតដើម្បីចាប់ពិរុទ្ធប្រព័ន្ធអ៊ីនធើណិតបានមានប្រសាសន៍ថា "យើងចង់ប្រាប់ដល់អ្នកប្រើប្រាស់អ៊ីនធើណិតទាំងអស់កុំឱ្យប្រើប្រាស់ពាក្យពេចន៍ទាក់ទងនឹងពាក្យអាសអាភាស និងពាក្យពេចន៍ទាក់ទងនឹងការស្អប់ខ្ពើម និងការបរិហារកេរ្តិ៍ជាដើម" ។

លោកបានបន្ថែមថា "ជាពិសេសអ្នកប្រើប្រាស់ហ្វេសប៊ុកត្រូវដឹងថា តើត្រូវគិតដល់កេរ្តិ៍ឈ្មោះ និងសេចក្តីថ្លៃថ្នូររបស់មនុស្សគ្រប់រូបផង" ។

លោក គីមសេង បានមានប្រសាសន៍ថា

តទៅទំព័រទី ១៨

# Seventeen Families Denied Plots in Kratie Land Reallotment

**BY AUN PHEAP AND GEORGE WRIGHT | SEPTEMBER 4, 2014**

Authorities in Kratie province's Snuol district on Wednesday furnished more than 300 families with long-awaited titles for land confiscated from a South Korean agribusiness firm on Saturday, but cut 17 families out of the deal because they lacked a legitimate claim to the plots they sought.

Provincial deputy Governor Khan Chamnan said that ownership documents were handed out to 312 families living on the 1,562-hectare tract confiscated from Horizon Agriculture Development, but that 17 families were denied plots because the land they wanted titles for had never belonged to the company, and was in fact state land.

"I wish to state that the confiscated land [claimed by the 17 families] did not belong to the company and there had been no pepper or rubber plantations," Mr. Chamnan said.

The deputy governor said authorities would register the additional 59 hectares for the 17 families if they could provide documents proving their claims that the land was measured for them as part of Prime Minister **Continued to Page 18**

**KhmerPost USA, LLC**
**សារពត៌មានខ្មែរផុសសហរដ្ឋអាមេរិក**
អាស័យដ្ឋាន 45 Merrimack St. Suite 218A. Lowell, MA 01852
លេខទូរស័ព្ទ Phone: 978 677-7163 | Fax: (978) 677-7092
អ៊ីម៉ែល info@khmerpost.us
អានកាសែតនៅគេហទំព័រ www.khmerpost.us
តាមដានយើងនៅទំព័រហ្វេសប៊ុក Like us at: www.facebook.com/KhmerPostUSA

ផ្សាយពាណិជ្ជកម្ម Advertising
អគ្គនាយកទីផ្សារ និងគ្រប់គ្រង សុបិន្ត ពិន Soben Pin, *Managing Partner*
លេខទូរស័ព្ទ 978 - 656 - 8141 (Mobile) 978 677-7163 (Office)
អ៊ីម៉ែលsobenpin@khmerpost.us

អ្នកនិពន្ធ Editorials
និពន្ធនាយក ពិន សំខុន Roger Samkhon Pin, *Publisher & Editor-in-Chief*
(978) 942 - 1641 | rogerpin@khmerpost.us

អ្នកនិពន្ធកិត្តិយស **Contributed Writers:**
Kim Phien, Richard Howe,Jr.

ច្នៃសោភ័ណភាពកាសែត **Design Artist**
Heng Chhunleng
ជំនួយការរដ្ឋបាល Intern
Moniphal Bing

KhmerPost USA, LLC is an independent newspaper that aims to facilitate mass communication among the Cambodian communities, their neighboring communities, and families. We aim to address local community, and national news; and give an insight into Cambodian & global news. We also strive to bridge the language and cultural gaps and reduce social isolation by publishing in Khmer & English. It published twice a month in Massachusetts serving Greater Lowell, Lynn, Revere, MA, Providence, RI, CT, NY, NJ, and Philadelphia, PA.

Mail subscription is available within the U.S. & Canada at 100.00 or 120 Euros in Europe per year.

The KhmerPost USA has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge effective date: 6/19/2009

**ប្រូវីជិនខ្មែរវីដេអូ**
មានជួសជុល និងលក់កុន
ចិន-ថៃ-ខ្មែរ-ឥណ្ឌា
គ្រប់ប្រភេទមានចម្រៀងសម័យវីដេអូ
ខារ៉ាអូខេថ្មីៗ
742 Potters Avenue
Providence, RI 02907
ទូរស័ព្ទ : (401) 787 6663

**សិក្សាពីឥស្លាម**
**សួរ :** មានចម្ងល់អ្វីទេពីឥស្លាម?
**ឆ្លើយ :** សូមទៅមើលគេហទំព័រ www.peacetv.tv ឬគេហទំព័រមួយទៀត www.gainpeace.com.
Q) Any Questions on Islam?
A)watch www.peacetv.tv
visit www.gainpeace.com.

**Health & Lifestyle Center**




រកគ្រូបង្ហាត់កីឡា កែររូបរាងកាយ – Full training
រកអ្នកជំនួយការ - Extra money part time
- Substancial money Full time
**Jack Silva** president and Wellness Coches
Health & Lifestyle Center 133 Merrimack St. Lowell
(603)264 6845 English -(978)942 1641 Khmer



# CLASSIFIED ADS




រឿងរាមកេរ្តិ៍ ដោយសាគូ សាមុត តម្លៃ $10




របាំបុរាណខ្មែរ ដោយសាគូ សាមុត តម្លៃ $10




រឿងរាមកេរ្តិ៍ ដោយសាគូ សាមុត តម្លៃ $10




ក្រុងភ្នំពេញមុនឆ្នាំ១៩៥៤ តម្លៃ $10




CAMBODGE តម្លៃ $5




អង្គការជានរណា? បភាគ តម្លៃ $5/1

**Your Bussiness Card is Here for $50/mon**
ពាណិជ្ជកម្មលោកអ្នកនៅទីនេះចំណាយត្រឹម តែ$50ក្នុង១ខែ

# ល្មមភ្ញាក់ខ្លួនហើយ ហើយនាំគ្នាសាងទំព័រ សារតាថ្មីឈប់ពឹងលើសត្រូវមកកាប់ សម្លាប់ជនជាតិឯងដើម្បីជ័យជំនះផ្ទាល់ខ្លួនតទៅទៀត

**ដោយ : គីម ភឿន**




ប្រវត្តិសាស្ត្របានបង្ហាញថា ពេលបុព្វបុរសយើងបែកបាក់គ្នាម្តងៗតែងតែម្ខាងទៅពឹងសៀមម្ខាងទៅពឹងយួនមកកាប់សម្លាប់ជនជាតិ ឯងរុករើដុតបំផ្លាញស្រុកភូមិខ្លួនឯង ដើម្បីជ័យជំនះផ្ទាល់ខ្លួន ឬក្រុមខ្លួនរួចកាត់ដីកាត់ទឹកព្រៃព្រឹក្សាជូនតាខ្លួនទៅឱ្យគេជាថ្នូរនឹងគុណរបស់គេបានមកបំផ្លាញសេចក្តីសុខសាន្តរបស់ជាតិឯង ។ រឿងនេះកើតឡើងដដែលៗច្រើនលើកច្រើនសារក្នុងសាវតាជាតិយើងតែបុព្វបុរសយើងមិនដែលដកបានការពិសោធន៍ម្តងណាសោះឱ្យតែមានរឿងបែកបាក់គ្នា គឺនាំគ្នាតម្រង់ទៅរកមាគ៌ាដដែលនេះ តែរៀងខ្លួនរហូតដល់ធ្លាក់ខ្លួនពីមហានគរមកដល់កូនប្រទេសមួយតូចដូចសព្វថ្ងៃកាលសម័យរុងរឿង(អង្គរ)មានប្រជាពលរដ្ឋជាង១០លាននាក់ ឥឡូវមួយពាន់ឆ្នាំក្រោយពីសម័យអង្គរចំនួនប្រជាពលរដ្ឋនៅតែចំនួនដដែលគួរណាស់តែកើនចំនួនដល់រាប់រយលានតែរវល់តែនាំសត្រូវបរទេសមកកាប់សម្លាប់បំភ្លេចបំផ្លាញ ទើបប្រទេសជិតខាងគេក្លាយជាគ្រោះភ័យសម្រាប់ការវិនាសបាត់បង់របស់ជនជាតិខ្មែរពីពិភពលោកនៅក្នុងអនាគត ព្រោះប្រជាពលរដ្ឋខ្លួនតិចទៅៗឯប្រជាជនគេកើតក្រោយតែមានកំណើនយ៉ាងឆាប់រហ័សបំផុត ។

សម័យថ្មីៗនេះដែលយើងកើតទាន់សឹងតែគ្រប់ៗគ្នានោះ គឺសម័យខ្មែរក្រហម គេខំដណ្តើមបានអំណាចហើយក៏ខំសម្លាប់ជាតិឯងតាំងពីកូនក្មេងរហូតដល់មនុស្សចាស់ជរាដោយបង្អត់បាយដោយឱ្យធ្វើការបាក់កម្លាំង មន្ទីរពេទ្យជាកន្លែងសម្រាប់ឃុំឃាំងអ្នកជំងឺឱ្យអត់ឃ្លានឱ្យឆាប់ស្លាប់ទៅវិញ ។ ផែនការណ៍របស់គេគឺចង់ឱ្យប្រជាពលរដ្ឋនៅសល់យ៉ាងតិចបំផុត ឱ្យអង្គការងាយត្រួតពិនិត្យ ហើយក៏ជាមធ្យោបាយផ្គាប់ចិត្តចៅហ្វាយខ្លួនដែលមានប្រជារាស្ត្រច្រើនខ្វះដីសម្រាប់រស់នៅ ។

ដល់ពេលដឹងថា យួនរៀបចំវាយប្រហារខ្លួនក៏តាំងនាំគ្នាបង្កើនចំនួនប្រជាជនដោយចាប់បង្ខំរៀបការជាសមោហភាពនឹងដោយបង្ខំ ។ តើលោកអ្នកដឹកនាំខ្មែរគិតអីចង់ទៅណា? នេះជាស្នាមប្រវត្តិសាស្ត្រអន់ថយអានឱនបំផុតរបស់អ្នកដឹកនាំខ្មែរក្នុងចំណោមបុព្វបុរសយើងតាំងពីជំនាន់កសាងទឹកដីនេះមក ។ យើងគ្មានវាចារនឹងស្តីបន្ទោសអស់លោកទាំងនោះទេ តែយើងចង់ឱ្យអ្នកដឹកនាំខ្មែរសម័យនេះយកគោលប្រវត្តិសាស្ត្រមកជាមេរៀន ។ បើនៅតែមិនភ្លឺភ្នែកទេ ខ្មែរមុខជាផុតពូជមិនខាន ។ ប្រសិនបើអស់លោកភ្ញាក់ខ្លួនទាន់ពេលនេះប្រហែលអាចនៅកែកុនព្រោះថ្នាក់រលាយបាត់ជាតិខ្មែរនេះបានខ្លះ បើបណ្តោយតទៅទៀតមើលទៅក្លាយជាចាមទៀតហើយ ។ សុខចិត្តចាញ់ ឬអត់ឱនគ្នាឯង ដើម្បីសេចក្តីល្អរបស់ជាតិយើងនេះវាថ្លៃថ្នូរណាស់តែបើឱបដៃសុខចិត្តចាញ់សត្រូវចាំតែតាមបង្គាប់បញ្ជាសត្រូវបរទេសបង្វិនបង្ហោចជាតិឯងនោះ វាពិតជាថោកទាបគួរតែស្លាប់ល្អជាង : សុខចិត្តធ្វើជាប្រេតអសូរិកាយថែរក្សាទឹកដីមាតុភូមិខ្លួនឯងវាប្រសើរជាងធ្វើស្តេចក្រោមបញ្ជាសត្រូវបរទេសរួចចង់ចាំតែតាមបង្គាប់បញ្ជាគេឱ្យបំផ្លាញជាតិខ្លួនឯងនោះខ្លាំងណាស់។ ល្មមភ្ញាក់ខ្លួនហើយ គ្មានអ្នកណាជួយយើង ស្រឡាញ់ជាតិយើងជាងខ្លួនយើងទេ ពឹងឱ្យបរទេសមកស្រឡាញ់ជាតិយើង គឺយើងវិនាសហើយ ចូរចាំសំដីនេះ ។ គួរស្រឡាញ់គ្នាឡើង ជូតទឹកភ្នែកឱ្យគ្នា ! ព្រោះយើងបានយំជាមួយគ្នាហួសនិស្ស័យនឹងយំទៀតហើយ ដូនតាយើងសឹងតែគ្រប់ជំនាន់ក៏បានយំសឹងគ្មានស្រាកស្រាន ព្រោះអ្នកដឹកនាំខ្មែរសឹងគ្រប់ជំនាន់រកមិនឃើញមធ្យោបាយដោះស្រាយការខ្វែងគំនិតគ្នានេះបានសោះនោះនោះ ម្យ៉ាងទៀតមកពីសត្រូវគេឆ្លាតវៃជាង គេបំបែកបំបាក់យើងបាន នាំឱ្យយើងឃើញតែផ្លូវមួយ គឺច្បាំងដណ្តើមយកឈ្នះតែរៀងខ្លួន ពេលបានឈ្នះហើយខំកំទេចឱ្យអស់ប្រឆាំងនឹងក្រុមខ្លួន ហើយសុខចិត្តរស់នឹងចែករំលែកអំណាចនឹងផលប្រយោជន៍ជាមួយសត្រូវរបស់ជាតិឯង រឿងណឹងកើតឡើងច្រំដែលរហូតដល់ជាតិសាសន៍យើងកំពុងស្ថិតនៅលើមាត់ជ្រោះមរណៈនេះឯង ។ អស់លោកជ្រាបគ្រប់គ្នាទាំងអស់ហើយថា ការសងសឹកគ្នាគ្មានទីបញ្ចប់ទេ ហើយទឹកដីនេះមិនមែនជារបស់ផ្តាច់មុខរបស់ក្រុមណាមួយទេ ជារបស់ខ្មែរយើងទាំងអស់គ្នា ចូរចេះស្តាប់គ្នា ដើម្បីរកផលប្រយោជន៍រួមជូនពលរដ្ឋខ្មែរឱ្យបានរស់នៅស្មើមុខមាត់គ្នា កុំឱ្យមានការជិះជាន់កេងប្រវ័ញ្ចគ្នាតទៅទៀត ហើយអស់លោកជាអ្នកដឹកនាំ អស់លោកជ្រាបច្បាស់ណាស់ថា ត្រូវធ្វើយ៉ាងណានោះ ។

ប្រទេសយើងមានឈ្មោះល្បីថា ជាប្រទេសគោរពបូជាព្រះពុទ្ធសាសនា នោះជាការល្អណាស់ប្រសិនបើរហូតពីអ្នកដឹកនាំកំពូលដល់ប្រជាពលរដ្ឋសាមញ្ញចេះគោរពឱវាទរបស់ព្រះពុទ្ធគ្រប់ៗគ្នា គឺប្រវត្តិសីល សមាធិនឹងបញ្ញាម្លេះសមគ្មានសង្ឃឹមកើតឡើងម្តងណាទេ តែអាស្រូវទាំងឡាយកើតឡើងនៅគ្រប់ជំនាន់ក្នុងប្រទេសយើងបាន គឺមកពីប្រទេសយើងគោរពសាសនាតែសំបកក្រៅខ្លឹមសារនៃព្រះពុទ្ធសាសនាមិនបានប្រតិបត្តិសោះឡើយ យើងយកតែសីលម្យ៉ាង មកសួរថាតើអ្នកដឹកនាំកំពូលយើងណាម្នាក់បានប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួនខ្លះពេលអស់លោកដឹកនាំប្រទេសជាតិ? សម្តេចសីហនុ ប៉ុល ពត លោក ហ៊ុន សែន ? លោកទាំងនោះបានគោរពសីល៥ ត្រឹមត្រូវឬទេ? គ្មានអ្នកណាមានសីលត្រឹមត្រូវទាល់តែសោះ យើងមិនបាច់និយាយពីសមាធិបញ្ញាអ្វីទៀតទេ យ៉ាងណឹងហើយប្រទេសយើងមានឈ្មោះតែសំបកទេ ណឹងហើយជាដើមចមនៃទុក្ខទោសកម្មពារវេរានៅក្នុងប្រទេសយើងមិនចេះចប់នោះទេ សីលធម៌ប្រទេសយើងធ្លាក់សឹងដល់កម្រិតសូន្យ ហើយលោកអ្នកដឹកនាំពេលនេះ គួរតែប្រញាប់ប្រញាល់នាំគ្នាគោរពច្បាប់សាងឡើងក្នុងសីលធម៌ខ្ពស់ដើម្បីសេចក្តីសុខក្សេមក្សាន្តនៃប្រទេសជាតិយើងទាំងអស់គ្នា ។

សន្ទុះនៃអ្នកចំណាកស្រុករាប់ម៉ឺនសែននាក់ទាំងមនុស្សពេញវ័យទាំងកូនក្មេងទាំងទារកឈឺចាប់ចាកចោលស្រុលភូមិគ្រាន់តែចង់បានស្បៀងចំអែតក្រពះស្រេកឃ្លានប៉ុណ្ណោះ ។ ស្រីក្មេងៗលាចាកម៉ែឪចាកចោលស្រុកភូមិទៅរកប្តីស្រុកគេក្នុងបំណងសល់លុយកាក់ខ្លះផ្ញើមកម៉ែឪឱ្យបានធូរធារខ្លះ ឬបានកែលម្អលំនៅដ្ឋានដែលសឹងតែបាក់បែកទ្រុឌទ្រោមអស់ទៅហើយ ។ នារីខ្លះមុជមិនជ្រៅទៅមិនឆ្ងាយសុខចិត្តឡើងមកក្រុងរកការងារធ្វើកម្មអកុសលក៏ធ្លាក់ខ្លួនទៅនៅក្នុងបនក្នុងបារ ក្មេងមិនទាន់ពេញវ័យខ្លះត្រូវឈ្មួញចាប់យកទៅលក់ឱ្យពួកអ្នកមានទ្រព្យសម្បត្តិសប្បាយនឹងបំផ្លាញព្រហ្មចារីយ៍ ឬម៉ែឪខ្លះដោយក្រីក្រពេកបាត់អស់ក្តីមេត្តាបានសុខចិត្តលក់កូនឱ្យគេដោយគ្នាមិនទាន់ដឹងក្តីរួចគ្នាត្រូវអ្នកមានទ្រព្យរំលោភបំពានដូចសត្វធាតុគ្មានត្រាប្រណី ! ឬត្រូវគេដឹកយកទៅជួញដូរនៅប្រទេសក្រៅរហូតដល់អស់ជីវិតមិនដឹងធ្លាក់ដល់ឋានណាឡើយ ។ ឯពលរដ្ឋកំពុងមានផ្ទះសម្បែងដីទឹកស្រែចំការរស់នៅសុខៗត្រូវដេញចេញពីផ្ទះអត់បាយហាលភ្លៀងខ្យល់ កេរ្តិ៍អាករខ្លួនត្រូវកម្មវិធីអភិវឌ្ឍន៍រឹបអូសយកដោយទុច្ចរិតអយុត្តិធម៌ដែលគេពុំធ្លាប់ដែលឃើញសោះតាំងពីខ្មែរកកើតទឹកដីមក ។

អស់លោកអ្នកដឹកនាំជាតិទាំងឡាយ កុំប្រាថ្នាធំមកលើខ្លួនឯងតទៅទៀត ជម្រះវិបត្តិសង្គមសព្វថ្ងៃឱ្យបានឆាប់ជាទីបំផុត គឺបំបាត់ពុករលួយ និងអំពើអយុត្តិធម៌ បើពុំធ្វើបានទេ កូនចៅគ្រួសាររបស់អស់លោកក៏ត្រូវរងកម្មដូចពលរដ្ឋខ្មែរដ៏ទៃទៀតដែរ នៅក្នុងអនាគតដ៏ខ្លីខាងមុខនេះ ព្រោះជាតិយើងនឹងក្លាយជាទាសករទាំងអស់គ្នា **តទៅលេខក្រោយ**



# ទឹកធ្លាក់ ភ្នំខៀវ





●●●រមណីយដ្ឋានទឹកធ្លាក់អូរតាវ៉ៅហៅ ទឹកធ្លាក់ភ្នំខៀវ មានទីតាំងនៅភូមិខ្លុង សង្កាត់ អូរតាវ៉ៅ ក្រុងប៉ៃលិន ខេត្តប៉ៃលិន តាមផ្លូវជាតិលេខ១០ មានចម្ងាយប៉ុន្មាន៨០គីឡូម៉ែត្រ ពីទីរួមខេត្តបាត់ដំបង ។ អ្នកទេសចរអាចងូតទឹក កម្សាន្តនៅទីនោះបានគ្រប់រដូវ ប៉ុន្តែនៅរដូវវស្សា មានទឹកធ្លាក់ខ្លាំង និងហូរត្របាញ់ខ្ជួលខ្ចាញ់ ឯរដូវប្រាំង ទឹកហូរតិចៗ ។ រមណីយដ្ឋានទឹកធ្លាក់នេះ បានបង្កើតឡើងនៅឆ្នាំ២០០៥ ក្រោមការវិនិយោគ ទុនរបស់ក្រុមហ៊ុន ពៅ សេងហាក់ ដែលមាន រយៈពេល៣០ឆ្នាំ បានចាប់ផ្តើមបើកឱ្យភ្ញៀវចូល មកកម្សាន្ត តាំងពីឆ្នាំ២០០៦មកម្ល៉េះ។ ទឹកធ្លាក់ នេះ មានប្រភពមកពីភ្នំខៀវដែលលាតសន្ធឹង ជាប់ព្រំប្រទល់ដែនកម្ពុជា-ថៃ ជាទឹកដីស្ថិតក្រោម ការគ្រប់គ្រងរបស់ពួកខ្មែរក្រហមកាលពីដំបូង។ អ្នកទេសចរដែលមកកម្សាន្តនៅទីនេះត្រូវបង់ប្រាក់ ៧.០០០រៀល សម្រាប់រថយន្តធុនធំ, ៥.០០០ រៀល សម្រាប់រថយន្តតូច, ឯម៉ូតូ,១០០០រៀល ដោយពុំគិតចំនួនមនុស្សជិះទេ ។ ក្រៅពីការងូត ទឹកកម្សាន្តអ្នកទេសចរអាចទិញម្ហូបអាហារ ដែលមានលក់នៅទីនោះ បរិភោគបានដោយងាយ ហើយក៏មានវត្ថុអនុស្សាវរីយ៍ផ្សេងៗធ្វើពីវល្លិ និង ផ្តៅផលិតដោយដៃប្រជាកសិករនៅមូលដ្ឋាននេះ សម្រាប់លក់ជូនផងដែរ ។ ដោយមានការយកចិត្ត ទុកដាក់ពីរាជរដ្ឋាភិបាល និងលោកអភិបាលខេត្ត ប៉ៃលិនទើបរមណីយដ្ឋានទឹកធ្លាក់នេះ ទទួលការ គាំទ្រពីអ្នកទេសចរគ្រប់មជ្ឈដ្ឋាន ។ សូម្បីតែ ជនបរទេស ក៏មកកម្សាន្តជាហូរហែដែរ ពិសេស នៅរដូវបុណ្យទានធំៗ ដូចជា បុណ្យចូលឆ្នាំខ្មែរ, ភ្ជុំបិណ្ឌ, ចូលឆ្នាំចិន ជាដើម ។ ដោយឡែកនៅឱកាសបុណ្យភ្ជុំបិណ្ឌនាឆ្នាំ២០១០នេះ ទឹកធ្លាក់ភ្នំខៀវ បានទទួលអ្នកកម្សាន្ត ជាមធ្យមមានរថយន្តតូចធំប្រមាណជាជាង២០០គ្រឿង និង ម៉ូតូជាង ៦០០គ្រឿង ឯអ្នក ជិះវិញគឺពេញៗសរុបទៅមាន មនុស្សមកទីនេះរាប់ពាន់នាក់ឯណោះ ។ ទឹកធ្លាក់ ភ្នំខៀវ មាន៧ជាន់ នៅជាន់ទី៧ ដែលមានចម្ងាយ ប្រមាណ៨០០ម៉ែត្រពីជាន់ទី៦ ពុំសូវមានអ្នក ទេសចរទៅដល់ទេ ព្រោះត្រូវដើរកាត់ព្រៃ ។ ភ្ញៀវ ទេសចរណ៍ជាច្រើនដែលពួកគាត់បានមកកម្សាន្ត នៅទីនេះ អារម្មណ៍ប្លែកភ្នែកណាស់ ព្រោះអ្វីៗ មានលក្ខណៈធម្មជាតិពិតៗ រួមទាំងបរិស្ថាន ក៏ មានការកែលម្អ គួរឱ្យទាក់ទាញ ។ ពួកគាត់ ធុញទ្រាន់នឹងបរិយាកាសដ៏អាប់អួ នៅទីក្រុង ដែលឮតែសន្ទឹកចរាចរណ៍ទ្រហឹងអឺងអាប់ជាមួយនឹងផ្សែងដែលចេញពីយានយន្តគ្រប់ប្រភេទ និងរោងចក្រ លុះមកជួបទិដ្ឋភាពដ៏ត្រកាល ឮសំឡេងទឹកធ្លាក់ឈូៗ ហូរត្របាញ់បែកផ្កាត្រែង ធ្វើឱ្យអារម្មណ៍របស់ពួកគាត់បានជួបទិដ្ឋភាពដ៏ កម្រនេះ ប្រែក្លាយជាស្រស់ស្រាយសប្បាយភ្លេចក្តីកើតទុកដែលដក់នៅជាប់ក្នុងសតិជាយូរមកហើយ នោះ។ គួរបញ្ជាក់ថា កាលពីសម័យសង្គ្រាមខេត្ត ប៉ៃលិន គឺជាតំបន់ប្រទាញប្រទង់រវាងកងកម្លាំង រដ្ឋាភិបាល នឹងកងទ័ពខ្មែរក្រហម ឯតំបន់ ទឹកជ្រោះសំខាន់ៗបានក្លាយជាជម្រកសត្វព្រៃ និងរងគ្រាប់កាំភ្លើងផ្លោងគ្រប់ធុន ។ មកទល់ពេល នេះស្រុកទេសបានសុខសន្តិភាពពេញលេញតំបន់ ទឹកធ្លាក់ភ្នំខៀវ ក៏បានក្លាយទៅជារមណីយដ្ឋានម្តង វិញ ដែលនឹងកំពុងតែទាក់ទាញអ្នកទេសចរឱ្យ ទៅកម្សាន្តជាហូរហែរ ៕





# វិធីថែរក្សាសម្រស់របស់ស្ត្រីមេផ្ទះ



សម្រាប់ស្ត្រីសម្រស់ប្រៀបដូចជាវត្ថុទិព្វប្រចាំកាយ ។ បើសិនជាបាត់បង់វត្ថុនេះ លោកស្រីអ្នកនាងកញ្ញានឹងក្លាយទៅជាមនុស្សស្រីដែលមិនមានការចាប់អារម្មណ៍ និងមិនគួរជាទីគយគន់ចំពោះអ្នកដទៃនោះទេ ។ ជាការព្រួយបារម្ភបំផុតនៅពេលដែលស្ត្រីបាត់បង់រូបសម្ផស្ស ។ ដូចនេះទោះបីជាលោកស្រីអ្នកនាងកញ្ញាក្លាយទៅជាភរិយាមួយរូបក៏ចាំបាច់ត្រូវគិតគូរពីបញ្ហាសម្រស់ជាសំខាន់ក្រៅពីការបំពេញតួនាទីជាស្ត្រីមេផ្ទះទុកដាក់កូនចៅរៀបចំផ្ទះសម្បែងយកចិត្ត និងថែទាំស្វាមី ។

លោកស្រី សាពណិ នាយិកាសាលាបង្រៀនកែសម្ផស្ស និងជំនាញក្នុងការរៀបចំគេហដ្ឋានបានបកស្រាយតាមរយៈវិធីថែរក្សាសម្រស់របស់ស្ត្រីមេផ្ទះ ។

**តួនាទីជាស្ត្រីមេផ្ទះ**

ជាទូទៅស្ត្រីមេផ្ទះមិនមានកិច្ចការងារអ្វីក្រៅពីរឿងផ្ទះសម្បែងនោះទេ ។ កិច្ចការរបស់ស្ត្រីមេផ្ទះ គឺជាភារកិច្ចដែលគប្បីបំពេញតួនាទីឱ្យគួរជាទីពេញចិត្តសម្រាប់គ្រួសារ ។ ការងារជាស្ត្រីមេផ្ទះមានច្រើនដូចជាការសម្អាតរៀបចំគេហដ្ឋាន ដើរផ្សារ ធ្វើម្ហូប អប់រំកូនៗ ផ្គាប់ចិត្តលោកប្តី និងមានកិច្ចការងារជាច្រើនទៀត ប៉ុន្តែក៏នៅមានពេលឆ្លៀតសម្រាកផងដែរ ។ ក្រៅពីការផ្គាប់ផ្គន់ចិត្តស្វាមី និងមើលថែអប់រំកូនៗស្ត្រីមេផ្ទះគួរត្រូវឆ្លៀតពេលវេលាដើម្បីថែរក្សាសុខភាព និងសម្រស់របស់ខ្លួនឯងផងដែរ ។

**ឆ្លៀតពេលគិតគូរពីបញ្ហាសម្រស់**

កិច្ចការរបស់ស្ត្រីមេផ្ទះនៅពេលព្រឹកគឺជាកិច្ចការធ្វើម្ហូបពេលព្រឹកជូនស្វាមី និងកូនៗរួចត្រូវដើរផ្សារទិញម្ហូបដើម្បីត្រៀមអាហារពេលថ្ងៃត្រង់ ។ បន្ទាប់មកគឺអាចមានពេលសម្រាករហូតជិតដល់ការរៀបចំម្ហូបអាហារថ្ងៃត្រង់ ។ ដូចនេះស្ត្រីមេផ្ទះគប្បីឆ្លៀតយកវេលានេះមកធ្វើការថែទាំសម្រស់របស់ខ្លួនដោយវិធីបិទម៉ាសលើផ្ទៃមុខវិធីថែរក្សាមុខដោយធម្មជាតិដោយយកបន្លែ ឬផ្លែឈើមកចិតបិទលើផ្ទៃមុខខាត់ស្បែកដោយសាប៊ូខាត់ស្បែកដោយខ្លួនឯង ឬក៏ទៅហាង ដើម្បីម៉ាស្សាមុខ ឬដងខ្លួនក៏បានដែរ ។ បើសិនជាគិតថា ពេលព្រឹកមិនសូវជាអាចឆ្លៀតពេលវេលាបាននោះទេ គឺអាចជ្រើសរើសយកពេលថ្ងៃបន្ទាប់ពីបាយថ្ងៃត្រង់ក៏បានដែរ ។ ការឆ្លៀតចំណាយពេលវេលាសម្រាប់ស្ត្រីមេផ្ទះ ដើម្បីថែទាំសម្រស់ខ្លួនឯងនោះ គឺអាស្រ័យទៅលើពេលវេលាអំណោយផល ។

**កុំគិតថាជារឿងចំណាយពេលច្រើន**

ជាទូទៅស្ត្រីមេផ្ទះមានការរវល់ច្រើនដែលស្ទើរតែគ្មានពេលគិតគូរពីបញ្ហាសម្រស់នោះទេ ៕


AccuCare
Home Care Agency
Group Adults Foster Care Program

## កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

Homecare Agency
Group Adult Foster Care Program (GAFC)
MassHealth

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្ដានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ



Compassionate Care & Reliable
Professional & Cultural Sensitive
Management & Staffs speak Khmer

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើង ដែលមានប ញ្ហារាំរ៉ៃផែកសុខភាព ឬជរាហើយមិនចង់ ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្តល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។

Accucare Homecare Agency is the perfect solution for seniors and others who are not ready to leave their home for an institutional setting or live with reltives because of illness or chronic conditions. We improve your life by providing one-on-one compassionate senior care in the comfort of your own home.

### ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :

To be eligibled for GAFC you must:

- រស់នៅផ្ទះរដ្ឋ (live in subsidized or public housing)
- អាយុ ២២ ឆ្នាំឡើងទៅ (age 22 years and older)
- មាស់ហែលស្តង់ដា (eligible for Masshealth Standard)
- ត្រូវការជំនួយក្នុងការរស់នៅប្រចាំថ្ងៃយ៉ាងហោចណាស់មួយដូចជា មុជទឹក ស្លៀក-ពាក់ ពេលប្រើបន្ទប់ទឹក ចំអិនអាហារ ឬ ពេលដើរ (need daily assistance with one or more personal care tasks such as bathing, dressing, toileting, meal preparation and/or moving)
- មានការអនុញ្ញាតពីគ្រូពេទ្យផ្ទាល់ខ្លួនអ្នក (have physician statement of your condition)
- ត្រូវបានវាយតំលៃផ្នែកសុខភាព និងការអនុម័តយល់ព្រមពីកម្មវិធី (be screened and approved for the program )

### ផលប្រយោជន៍ទទួលបាន :

Benefits you will get:

- ការថែទាំផ្ទាល់ខ្លួនមួយទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ (personal care service in your home, up to one hour of service each day)
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក (Medication Managemant)
- ផែនការថែរទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីយើ (an individual care plan developed by a registered nurse and case manager)
- វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់ (ongoing monitoring of needs)
- សមាជិកអាចទាក់ទងមក ២៤ម៉ោង (24-hour access to services)

**ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed for Lowell, Lynn, Revere, and Boston**

**ដើម្បីចុះឈ្មោះសូមទាក់ទងមក**
To register, please contact:

ឱក តុលាយុត្តិ ឡូវែល
Tolayuth Ok: Lowell
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

# ខ្មែរអ្នកជាតិនិយម

**តពីលេខមុន**




ក៏បានរៀបចំបញ្ជូនគណៈប្រតិភូមួយទៅភ្នំពេញឱ្យធ្វើការទាក់ទងជាមួយរាជរដ្ឋាភិបាល ដើម្បីឱ្យកងកម្លាំងរំដោះនៃចលនាឥស្សរៈរួមខ្មែរបំរើជាតិបានចូលរួមក្នុងមហាសង្គមជាតិជាលើកទី២ ដោយហេតុថា នៅឆ្នាំ១៩៥៤ កងកម្លាំងរំដោះនៅភាគឧត្តរទិស និងនៅភាគបស្ចិមទិស បានប្រមូលជួបជុំគ្នានៅលើភ្នំដងរែកស្រេចហើយ ត្រៀមរៀបចំចូលរួមក្នុង ពិធីបុណ្យអបអរសាទរចំពោះសេចក្តីសម្រេចចិត្តនៃអង្គប្រជុំសន្និសីទក្រុងហ្សឺណែវ ព្រមទាំងត្រៀមខ្លួនចូលរួមក្នុងមហាសង្គមជាតិវិញ ។

ថ្ងៃទី៣០ កញ្ញា ១៩៥៤ កងកម្លាំងរំដោះដែលត្រូវចូលរួមនៅលើកទី២ នេះ បានធ្វើដំណើរទៅចូលរួមជាមួយរាជរដ្ឋាភិបាលនៅត្រង់តំបន់ស្រុកក្រឡាញ់ ខេត្តសៀមរាប ។

ចំណែកឯលោក សឺន ង៉ុកថាន់ ដែលស្តេចសីហនុ មិនអនុញ្ញាតឱ្យចូលគាល់នោះ ក៏ត្រូវត្រឡប់ទៅរស់នៅលើភ្នំដងរែកវិញ ធ្វើស្រែចម្ការនៅតំបន់អូរស្មាច់ ស្រុកសំរោងចុងកាល់ ខេត្តសៀមរាប ជាមួយសហការីមួយចំនួនមានលោក ងួន ហុង និងខ្លួនខ្ញុំ (ឡឹក សំអឿន) ។ល។ ឯលោកកៅ តក់ ព្រមទាំងសហការីមួយចំនួន ដូចយ៉ាងលោក សុខ មាន ជាដើម ក៏បានវិលត្រឡប់ទៅរស់នៅក្នុងតំបន់ប្រាសាទតាមាន់ និងតំបន់គូដែលនៅជាប់បន្ទាយឆ្មារ (តំបន់ទាំង២នេះ ចលនាឥស្សរៈរួមខ្មែរបំរើជាតិបានរៀបចំឱ្យមានរបរកសិកម្ម និងចិញ្ចឹមសត្វតាំងពីសម័យតស៊ូម្លេះ) ។

តាមមតិអ្នកជាតិនិយម គេបានកត់សម្គាល់ថា ដែលស្តេចសីហនុ មិនព្រមទទួលឱ្យលោក សឺន ង៉ុកថាន់ ចូលគាល់ព្រះអង្គ ដើម្បីពិភាក្សាបញ្ហានយោបាយប្រទេសជាតិនោះ មានហេតុបច្ច័យច្រើនយ៉ាងណាស់ តែគេអាចចងបានជា ២ ចង្កោមធំៗ គឺ:

**ទី១ -** ព្រះអង្គកើតជំងឺច្រណែន -ច្រណែននឹងលោក សឺន ង៉ុកថាន់ ដែលមានប្រជាប្រិយភាព និងសមត្ថភាពខាងផ្លូវនយោបាយក្នុងការបំរើជាតិខ្ពស់ជាងព្រះអង្គឆ្ងាយណាស់ តួយ៉ាងដូចជារាជសម្បត្តិព្រះអង្គ និងកិច្ចការនយោបាយប្រទេសជាតិ តាំងពីពេលដែលទ្រង់បានឡើងសោយរាជ្យមកសុទ្ធតែជាស្នាដៃរបស់លោក សឺន ង៉ុកថាន់ ទាំងអស់ ។

**ទី២ -** ទ្រង់ខ្លាចក្រែងលោក សឺន ង៉ុកថាន់ ដណ្តើមអំណាចរំលាយរាជសម្បត្តិរបស់ព្រះអង្គ ។

**រឿងនេះ កើតមកពីមូលហេតុ ២ យ៉ាងគឺ :**

**១-** ពួកអ្នកនៅជុំវិញស្តេចសីហនុ ដែលភាគច្រើនជាមនុស្សពុករលួយពូកែលុយក្រាបយកគាប់តែងញុះញង់ផ្លុំត្រចៀកស្តេចជានិច្ច ព្រោះបើស្តេចទទួលយកលោក សឺន ង៉ុកថាន់ មកនៅជិតជួយកិច្ចការនយោបាយប្រទេសជាតិដូចសម័យឆ្នាំ ១៩៤៥ នោះ ពួកគេប្រាកដជានឹងខូចខាតផលប្រយោជន៍ ឬអាចនឹងរលាយបាត់សាបសូន្យផង ។

**២-** ក្រុមដែលមានឥទ្ធិពលយ៉ាងខ្លាំងក្លាទៅលើតួអង្គស្តេចសីហនុ ហើយមានអានុភាពរុញច្រានឱ្យព្រះអង្គហ៊ានប្រឆាំងនឹងការណែនាំទូន្មាននៃព្រះរាជមាតាបិតាព្រះអង្គ មិនត្រឹមតែកិច្ចការសាមញ្ញក្នុងរាជវង្សប៉ុណ្ណោះទេ គឺរហូតដល់កិច្ចការជាអាយុជីវិតរបស់ប្រទេសជាតិទៀតផង ។ ក្រុមនេះគឺ ស្រីស្រស់រូបឆើត ដែលមានពួកអ្នកអែបអបដើម្បីបុណ្យស័ក្តិនឹងអ្នកនយោបាយសម្ដីករណេបរណឹបនៅពីក្រោយ ដើម្បីធ្វើវិទ្ធង្សនាទៅថ្ងៃក្រោយទៅទៀត ។

តាំងពីបានឯករាជ្យមកគេមិនដែលឃើញសម្តេចឧបយុវរាជសីហនុធ្វើនយោបាយបង្រួបបង្រួមឱ្យមានសាមគ្គីភាពក្នុងសង្គមជាតិទេ ផ្ទុយទៅវិញ ទ្រង់អនុវត្តតែវិធានការញុះញង់បំបែកបំបាក់ឱ្យមានការប្រេះឆានៅក្នុងសង្គមជាតិជានិច្ច ដើម្បីឱ្យងាយស្រួលត្រួតត្រាសង្កត់សង្កិន ។

ចំណែកលោក សឺន ង៉ុកថាន់ វិញ លោកតែងតែមានបំណងចង់ឃើញប្រជាជាតិខ្មែរមានសាមគ្គីធម៌ជានិច្ច ព្រោះលោកយល់ច្បាស់ថា សាមគ្គីធម៌ជាផ្លូវតែមួយគត់ ដែលប្រជាជាតិខ្មែរយើងត្រូវប្រើជាដរាប ដើម្បីរួមគ្នាប្រឈមមុខទល់នឹងអន្តរាយគ្រប់យ៉ាង ដែលមាន ហ្វូ ជីមិញ ជាមេដឹកនាំ ក្នុងគោលបំណងលេបទឹកដីខ្មែរ ។ លោក សឺន ង៉ុកថាន់ បានខំព្យាយាមគ្រប់មធ្យោបាយក្នុងការស្វែងរកសាមគ្គីធម៌នេះជាដរាប ។ ក្រោយពីបានទាក់ទងតាមរយៈវរជនខ្មែរមានព្រះរាជមាតាបិតានិងសម្តេចព្រះអង្ឃរាជទាំងពីរគណៈជាដើមពុំបានសម្រេចផលនោះ លោក សឺន ង៉ុកថាន់ **តទៅលេខក្រោយ**

## តមកទំព័រទី ១៣ រដ្ឋាភិបាលមានគម្រោងហាមប្រាម...

ក្រសួងមិនទាន់បានកំណត់ពេលវេលាសម្រាប់គំនិតផ្តួចផ្តើមនេះនៅឡើយទេ ប៉ុន្តែលោកបានមានប្រសាសន៍ថា ក្រុមមន្ត្រីកំពុងចងក្រងពាក្យពេចន៍ដែលត្រូវហាមប្រាមរួចហើយ។

លោកបានមានប្រសាសន៍ថា "ឧទាហរណ៏ប្រសិនបើនរណាម្នាក់ចោទបុគ្គលម្នាក់ថាក្បត់ជាតិ ឬបង្ហោះរូបថតបង្ហាញពីសកម្មភាពសម្លាប់ ឬហិង្សាជាដើម។ យើងកំពុងសិក្សាថា តើត្រូវដោះស្រាយបញ្ហានេះដូចម្តេច"។

លោក ផា ច័ន្ទបរិបូណ៌ រដ្ឋលេខាធិការក្រសួងព័ត៌មានបានមានប្រសាសន៏ថា ការហាមប្រាមនេះ គឺជាគំនិតរបស់លោកគឹមសេង ហើយបានបដិសេធមិនធ្វើអត្ថាធិប្បាយបន្ថែមឡើយ។

ដោយសំដៅដល់លោក គឹមសេង លោក ផា ច័ន្ទបរិបូណ៌ បានមានប្រសាសន៏ថា "គាត់គឺជាអ្នកដែលបានស្នើគំនិតនេះ។ សូមសួរគាត់ទៅ"។

ខណៈដែលក្រុមមន្ត្រីបានបដិសេធមិននិយាយថា តើការហាមប្រាមនេះនឹងអនុវត្តដូចម្តេចនោះ ម្ចាស់ក្រុមហ៊ុនអ៊ីនធើណិតមួយបានលើកឡើងថា លោកនឹងអនុវត្តតាមប្រសិនបើត្រូវបានស្នើសុំឱ្យបិទគេហទំព័រមួយចំនួននោះ។

លោក សុខ ចន្ទា នាយកប្រតិបត្តិក្រុមហ៊ុនមេគង្គណិត បានមានប្រសាសន៏ថា "ខ្ញុំនឹងធ្វើតាមច្បាប់ប្រសិនបើក្រសួងចេញពាក្យហាមប្រាមនោះ។ ក្រសួងអាចដកអាជ្ញាប័ណ្ណរបស់ខ្ញុំបានប្រសិនបើខ្ញុំមិនអនុវត្តតាម"។

លោក ព្រាប កុល នាយកប្រតិបត្តិអង្គការតម្លាភាពកម្ពុជាបានថ្កោលទោសគំនិតផ្តួចផ្តើមនេះ។ លោកបានមានប្រសាសន៏ថា "វាជាវិធានការគួរឱ្យព្រួយបារម្ភ។ ប្រសិនបើទំហំ និងការកំណត់ភាសាដាក់កម្រិតទៅលើសេរីភាពនៃការបញ្ចេញមតិនៅពេលគេសំដៅដល់ទស្សនៈនយោបាយ ឬការនិយាយរិះគន់នោះ វាអាចបង្កើតជាការចាប់ពិរុទ្ធ និងអាចប៉ះពាល់អវិជ្ជមានដល់សេរីភាពនៃការបញ្ចេញមតិ"៕ **សារុន**

**Continued from Page 13**

## Seventeen Families Denied Plots...

Hun Sen's 2012 land-titling scheme.

Mr. Chamnan acknowledged that some of the 17 families had already produced such proof, but said the documents submitted were not sufficiently detailed.

Land Management Minister Im Chhun Lim intervened in the high-profile dispute on Saturday, announcing that Horizon Agriculture's claim to the contested area would be revoked and divided up among the protesting villagers because the company had not developed the land.

One villager who did not receive a title Wednesday, Yen Senghong, 57, said she would protest her exclusion after first consulting with village representatives.

"I was very happy when Excellency Im Chhun Lim announced that he would give the land back to all the protesters, but I was very disappointed when authorities told me my document was not sufficient to get a land title," Ms. Senghong said.

Horizon Agriculture director Lim Jo-heon said company representatives planned to meet with officials from the Land Management Ministry this week to discuss compensation for the company, or possibly a new concession.

"Our company got a message from Land Management Department saying that they will invite us within few days and will explain to us their final decision," Mr. Jo-heon said in an email.

"At a previous meeting with them they mentioned about compensation [or] a new concession land so we have to see the final offer before the company takes a next step."

Mr. Jo-heon added that he was still displeased about the government's decision to confiscate the land.

"If people really lived there, then it means thousands of people lived there and must be almost the biggest town in that area which is nonsense," he said.

# កាហ្វេ ២ពែងក្នុងមួយថ្ងៃអាចឱ្យកូនក្នុងផ្ទៃប្រឈមនឹងជំងឺមហារីកគ្រាប់ឈាម



ស្ត្រីដែលកំពុងពពោះ ហើយទទួលទានកាហ្វេ២ពែង ឬច្រើនជាងនេះក្នុងមួយថ្ងៃ នឹងធ្វើឱ្យកូនក្នុងផ្ទៃប្រឈមនឹងជំងឺមហារីកគ្រាប់ឈាម ឬដែលយើងនិយមហៅថាឈាមសស៊ីឈាមក្រហមខ្ពស់នៅពេលកើតមក។ សារជាតិកាហ្វេអាចផ្លាស់ប្តូរ DNA នៅក្នុងកោសិការបស់ទារកមិនទាន់កើតដែលជាហេតុធ្វើឱ្យពួកគេងាយទទួលរងជំងឺនេះ។

អ្នកស្រាវជ្រាវបានធ្វើការសិក្សាទៅលើស្ត្រីកំពុងពពោះជាង២០នាក់ ដែលបានទទួលកាហ្វេរកឃើញថា ២០ភាគរយនៃគភ៌ក្នុងផ្ទៃកំពុងប្រឈមនឹងជំងឺមហារីកគ្រាប់ឈាមនៅពេលកើតមក។ ប្រសិនបើអ្នកម្តាយទាំងនោះពិសាកាហ្វេរហូតដល់២ពែង ឬច្រើនជាងនេះក្នុងមួយថ្ងៃហានិភ័យនឹងកើនឡើងរហូតដល់៦០ភាគរយ។ ការសិក្សាដែលចេញផ្សាយដោយសារព័ត៌មានអាមេរិកបានបញ្ជាក់ទៀតថា ប្រសិនបើកាហ្វេដែលទទួលទានមានចាប់ពី៤ពែងឡើងទៅកូនក្នុងផ្ទៃនឹងប្រឈមជំងឺនេះដល់ទៅ៧២ភាគរយ។



មហារីកគ្រាប់ឈាមគឺជាប្រភេទជំងឺម្យ៉ាងដែលប្រជាជនខ្មែរនិយមហៅថា ឈាមសស៊ីឈាមក្រហម។ ជាទូទៅកោសិកាមហារីកគ្រាប់ឈាមដែលបណ្តាលពីការខូចខាតនៃគ្រាប់ឈាមសរីកដុះដាលដោយអនាធិបតេយ្យមិនអាចគ្រប់គ្រងបានទេ។ វាបានទៅរំខានទៅដល់ការផលិតគ្រាប់ឈាមក្រហមធ្វើឱ្យអ្នកជំងឺខ្វះគ្រាប់ឈាមក្រហម។ ប្រសិនបើមិនបញ្ចូលឈាមឱ្យអ្នកជំងឺទេនោះ វានឹងអាចបណ្តាលឱ្យស្លាប់៕




**ហាងខ្មែរជួសជុលរថយន្ត**

**បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ**

**Rathe´s Auto Service**

State and Emission Inspaction General Repairs and Maintenance

MON-SAT, 8:30AM-5:30PM
SUN. EMERGENCY ONLY




- ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
- មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត។
- មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ
- មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : - ដូរប្រេងក៏រិត ៥ ក្វាត $22
- INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ តាក់ -មានជូនប័ណ្ណពិសេសសំរាប់ដូរប្រេងចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
- តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត។
- ប្តេជាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ។ ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL : (215) 329-2418
Fax : (215) 329-2419. Rath CELL : (215) 431-6376



**ANGKOR AUTO SERVICE,INC.**

**ហាងជួសជុលរថយន្ត "អង្គរ"**

Free Estimate

Auto Body and Maintenance



BODY WORKS
Auto glass and windshields
Auto Frame Straightening and Painting

មានបទពិសោធន៏២០ឆ្នាំ ជាជាងរថយន្តមានសញ្ញាប័ត្រវាយតម្លៃការងារដោយឥតយកថ្លៃ ហើយយើងជួយសន្សំប្រាក់តម្លៃបន្ថយរបស់អិនស្វ៊ិនបានផង យើងផ្តល់សេវាគ្រប់យ៉ាង :

ENGINE AND TRANSIMISSION SERVICES
State Inspection
Check Engine Light Diagnostic
Timing Belt Services
Complete Tune Up:
-Brake -Muffler -Struts
-Water Pump -A/C
-Bearing Services



From the moment you get into car accident, we will take care of you from towing to calling your insurance, and to get a rental car for you. With Angkor Auto, you can be worried free.

4835 N. 16th Street. Philadelphia, PA 19141
Tel : (215) 455-7810 / Ricky : (215) 485-1425

# Connect with over 20,000 residents in Lowell!




Soben Pin, Managing Partner




KhmerPost USA - Your portal to the 2nd largest Cambodian-American population in the United States

Free Full Color Biweekly Bilingual Cambodian-American Newspaper available over 100 locations serving Greater Lowell, Lynn, Boston and beyond.

**Call 978-677-7163** for a free quote today!

You Tube

សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា
KhmerPost USA

KhmerPost USA | 45 Merrimack St., Suite 218A | Lowell, MA, 01852
Phone: 978.677.7163 | Fax : 978-677-7092
www.khmerpost.us | Info@khmerpost.us

# រោងជាង រថនា

**LEGEND AUTO BODY INC.**

អាស័យដ្ឋាន 115 Rock St. #7 Lowell, MA 01854

សូមទំនាក់ទំនង **អាដាំ ថ៊ា** : **978-458-2085**

**ជួសជុលយានយន្តលោកអ្នកប្រកបដោយគុណភាព**

Lowell Finest Quality of Body Work

**មានបម្រើ**

- ជួសម៉ាស៊ីនយានយន្ត
- ប្រភេទយានយន្តក្នុង និងក្រៅប្រទេស

**តួយានយន្ត**

- បញ្ជាក់បណ្ណធានារ៉ាប់រងទទួលស្គាល់ដោយរដ្ឋ

**ដឹកឡានត្រូវចង់** 978-815-9957 (ខេ-ស៊ី)



**115 Rock St. Unt #7 Lowell, MA 01854**

# រោង ជាង រថនា




**AUTO BODY INC.**
**(978) 458-2085**

**Services**

- Auto Body
- Auto Mechanics
- Foreign and Domestics
- State and Insurance Certified

Towing - **978-815-9957** (K.C)




# GATEWAY FAMILY DENTAL

www.gatewayfamilydental.com • **(978) 455-5044**

**151 WARREN STREET, SUITE 120 LOWELL, MA 01852 (Same building as Social Security/near the courthouse)**



**DR. SERENA B. CHUOP**

Dr. Serena B. Chuop was born in Cambodia. She received her Bachelor of Science from Boston University and went on to graduate from Boston University Goldman School of Dental Medicine in the year 2000. For over 13 years, she has been in private practices providing all aspects of General Dentistry. Her state of the art dental practice includes digital x-rays, paperless patient chart system, and new dental equipments.




**WE PROVIDE ALL SERVICES INCLUDING:** **យើងផ្តល់នូវសេវាដូចខាងក្រោមនេះ**

- CLEANING
- FILLINGS
- BONDINGS
- COSMETIC DENTISTRY
- CROWNS/BRIDGES
- DENTURES
- IMPLANTS
- EXTRACTIONS
- TEETH WHITENING
- VENEERS
- EMERGENCY DENTAL TREATMENT
- ROOT CANAL TREATMENT
- DENTAL SERVICES TO CHILDREN

- សំអាតធ្មេញ
- បំពេញធ្មេញប្រហោង
- ថ្នាំសំរាប់ការពារធ្មេញ
- ធ្មេញពាក់ជំនួសធ្មេញ ដែលបាក់
- ក្រាសធ្មេញពាក់
- ដាំធ្មេញតាមទន្ធធ្មេញចាស់
- ដកធ្មេញ
- ធ្វើធ្មេញឱ្យសស្អាត
- វ៉ែរនីស្រោបធ្មេញ
- ព្យាបាល និងការពារ ធ្មេញជាទៀងទាត់
- ព្យាបាល ឫសថ្គាមធ្មេញ
- សេវាព្យាបាលសំរាប់កុមារ

Free Teeth Whitening Kit
(with new patient´s x-ray, exam, cleaning at regular price)

**MOST DENTAL INSURANCES ACCEPTED**
**INCLUDING MASSHEALTH**
**FINANCING AVALIABLE**

**យើងទទួលនូវគ្រប់ អ៊ិន ស៊ូរិន**
**Masshealth**
**យើងសំរួលការបង់ថ្លៃព្យាបាលប្រចាំខែ**

**CALL FOR YOUR FREE CONSULTATION**
**(978) 455-5044**



# ជោគជតារាសីលោកអ្នក ទាំង១២ ប្រចាំឆ្នាំរោង

## ឆ្នាំជូត



រាល់កិច្ចការដែលលោកអ្នកប៉ងប្រាថ្នាជាយូរមក ហើយនោះក្នុងរយៈពេលនេះ គឺបានសមដូចបំណង ហើយគ្មានអ្វីមករារាំងនោះទេ ហើយរាល់ការប៉ងយាយីពីមនុស្សដែលមានបំណងមិនល្អមកលើលោកអ្នកនោះក៏មិនបានសម្រេចដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញអាចពង្រីកអាជីវកម្មឱ្យធំបន្ថែមទៀតបាន ។ ឯបញ្ហាស្នេហាគូស្វាមីភរិយាមានភាពសុខដុមរមនាគ្មានផលរមាស់អ្វីឡើយ ៕

## ឆ្នាំឆ្លូវ



លោកអ្នកគួរប្រុងប្រយ័ត្នចំពោះការនិយាយស្តីបន្តិច ពីព្រោះអាចនឹងមានគូសត្រូវចាំចាប់ទោសកំហុសមួលបង្កាច់បង្ខូចកេរ្តិ៍ឈ្មោះរបស់លោកអ្នកឱ្យប្រែក្លាយទៅជាស្មុយអសោចិ៍ ។ សម្រាប់អ្នកប្រកបមុខរបររកស៊ីជួញដូរវិញមានក្រុមមនុស្សតាមឈ្នានីសច្រើន ដូចច្នេះត្រូវប្រយ័ត្នបន្តិចចៀសវាងការបរាជ័យ ។ រីឯបញ្ហាស្នេហាមានភាពចម្រូងចម្រាសដាក់គ្នាបន្តិចបន្តួច ៕

## ឆ្នាំខាល



លោកអ្នកអាចនឹងមានអារម្មណ៍ច្របូកច្របល់បន្តិចនៅក្នុងរយៈពេលនេះ ព្រោះកិច្ចការដែលថា នឹងទទួលបានផលល្អនោះ វាអាចមានការប្រែប្រួលដោយសារតែមានការរំខានពីអ្នកដទៃ ។ បើចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ អាចរកផលកម្រៃគ្រាន់ បើគួរជាទីគាប់ប្រសើរជាងមុន ។ រីឯបញ្ហាស្នេហាពុំមានផលរមាស់អ្វីនោះឡើយ ៕

## ឆ្នាំថោះ



រាល់ការបំពេញការងាររបស់លោកអ្នកក្នុងរយៈពេលនេះសុទ្ធតែផ្តល់នូវអត្ថប្រយោជន៏ គួរឱ្យជាទីពេញចិត្តទាំងអស់គ្មានអ្វីមករាំងស្ទះឡើយ ហើយជាងនេះទៀត នោះគម្រោងការដែលបានត្រៀមទុកជាយូរមក ហើយក៏នឹងបានសម្រេចផងដែរ ។ បើជាអាជីវករកស៊ីវិញ មានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ រីឯបញ្ហាគូស្នេហ៍ច្រើនយល់ចិត្តគ្នា និងនឹករលឹកគ្នា បើនៅឆ្ងាយ ៕

## ឆ្នាំរោង



លោកអ្នកមានភ័ព្វសំណាងល្អក្នុងការងារទទួលរឿងឡើងតួនាទី ឬប្រាក់បៀវត្សរ៍បន្ថែម ។ ជាងនេះទៀតនោះប្រសិនបើចង់ពឹងពាក់អ្នកមានយសស័ក្តិខ្ពង់ខ្ពស់ក្នុងរឿងអ្វីមួយនឹងបានដូចបំណងផងដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញ អាចរកប្រាក់ចំណូលចិញ្ចឹមគ្រួសារបានដោយស្រួលទេ មិនមានអ្វីមករាំងស្ទះឡើយ ។ រីឯបញ្ហាស្នេហាគូស្នេហ៍រមែងចេះអត់ឱនឱ្យគ្នា ៕

## ឆ្នាំម្សាញ់



រាល់ការស្មុគស្មាញដែលធ្លាប់កើតមានលើលោកអ្នកក្នុងពេលនេះ នឹងត្រូវអហោសិកម្មទាំងអស់ ហើយទ្រព្យដែលរបូតចេញពីដៃទៅនឹងវិលត្រឡប់មកវិញយ៉ាងគ្រប់គ្រាន់ ។ ចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ ត្រូវគិតគូរឱ្យបានច្បាស់លាស់មុននឹងដាក់ទុនថ្មីទើបមិនខាតបង់រាល់ការចំណាយទាំងនោះ ។ រីឯបញ្ហាស្នេហាត្រូវចេះពូនជ្រោយចំណងស្នេហាដោយមានភាពផ្អែមល្ហែមទើបជាការប្រសើរ ៕

## ឆ្នាំមមី



រាល់ការបំពេញការងារទាំងឡាយលោកអ្នកមិនមានបញ្ហាអ្វីចោទនោះទេ ប៉ុន្តែក្នុងនោះ សូមប្រយ័ត្នកុំយកអាសាមនុស្សសម្បុរសឱ្យសោះ ព្រោះនាំឱ្យកើតរឿងសៅហ្មងទៅថ្ងៃក្រោយ ។ សម្រាប់អ្នកប្រកបមុខរបររកស៊ីជួញដូរវិញ អាចសន្សំទុកបានខ្លះ ។ រីឯបញ្ហាស្នេហាចូរកុំយកភាពមានះចង់ចាញ់ឈ្នះប្រយ័ត្នកើតមានជម្លោះវិវាទឈានដល់ការប្រេះស្រាំ ៕

## ឆ្នាំមមែ



លោកអ្នកនឹងទទួលបាននូវលាភសក្ការៈពីភាគហ៊ុនរកស៊ី និងមិត្តរួមការងារយ៉ាងច្រើនគួរឱ្យពេញចិត្ត ។ លើសពីនេះទៅទៀតគម្រោងការដែលបានត្រៀមទុកនឹងបានសម្រេចដូចបំណងទៀតផង ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញ គួរជួញដូរនៅទីជិតៗទើបសមប្រកប ។ រីឯបញ្ហាស្នេហាគូស្នេហ៍ចេះស្តាប់ឱវាទគ្នា ៕

## ឆ្នាំវក



ក្នុងរយៈពេលនេះលោកអ្នកជួបនឹងបញ្ហាខាងផ្លូវចិត្តមិនសូវជាសប្បាយរីករាយប៉ុន្មាននោះទេ តែប្រសិនបើចង់ទទួលផលពីការងារនោះ ចូរធ្វើចិត្តឱ្យត្រជាក់ ទើបបានសម្រេចដូចបំណង ។ បើជាអ្នកប្រកបរបររកស៊ីជួញដូរវិញ គឺមានការប្រទាំងប្រទើសជាមួយអ្នកមានមុខរបរដូចគ្នា ដូច្នេះគួរបើកចិត្តឱ្យទូលាយ ។ រីឯបញ្ហាស្នេហាមានការកាំចិត្ត ព្រោះតែម្នាក់ៗចង់ចាញ់ឈ្នះគ្នានោះឯង ៕

## ឆ្នាំរកា



នៅក្នុងរយៈពេលនេះ លោកអ្នកទទួលលាភសក្ការៈពីសាច់ញាតិបងប្អូនដែលជិតស្និទ្ធ ។ ក្រៅពីនោះក៏នៅទទួលបានដំណឹងល្អដែលមានប្រយោជន៏ដល់ជាតិ និងការងាររបស់លោកអ្នកតទៅអនាគតទៀតផង ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញផលកម្រៃទទួលបានកាក់កបគ្រាន់បើតែហាមកុំជួញដូរផ្លូវឆ្ងាញប្រយ័ត្នមានបញ្ហាដល់ខ្លួន ។ រីឯបញ្ហាស្នេហាគូស្នេហ៍អាចមានការរកាំរកូសគ្នាខ្លះ ប៉ុន្តែមិនធ្ងន់ធ្ងរនោះទេ ៕

## ឆ្នាំច



អាចពោលបានថា លោកអ្នកមានសេចក្តីសុខក្នុងជីវិត និងការងារ ព្រោះវិបត្តិ និងភាពស្មុគស្មាញដែលមានកន្លងមកក៏បានធូរស្រាលឡើងវិញមួយកម្រិតផងដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញ ទោះបីជាចេញទៅជួញដូរនៅទីណាក្តី គួរចៀសវាងការដាក់ទុនថ្មីព្រោះអាចនាំឱ្យខាតបង់ ។ រីឯបញ្ហាស្នេហាគូស្នេហ៍ច្រើនប្រចណ្ឌខុសរឿង ៕

## ឆ្នាំកុរ



រាល់កិច្ចការសព្វបែបយ៉ាងលោកអ្នកអាចជួបនឹងបញ្ហាខ្លះៗ នាគ្រាដំបូង ប៉ុន្តែក្រោយមកមិនមានអ្វីជាឧបសគ្គរារាំងទៀតឡើយ ។ ចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ មានការទិញចូលលក់ចេញគ្រាន់ បើអាចរកផលកម្រៃត្រឡប់មកផ្ទះវិញ យ៉ាងត្រជាក់ចិត្ត ។ រីឯបញ្ហាស្នេហាមានភាពផ្អែមល្ហែម និងស្រស់ស្រាយប្រៀប ដូចត្រីក្នុងទឹកនារដូវខែវស្សាដូច្នេះដែរ ៕

តមកពីទំព័រទី ១២
## អតីតនាយករដ្ឋមន្ត្រីគាំទ្រការកំណត់...

តំណែងលោក ប៉ែន សុវណ្ណ នៅពេលលោក ត្រូវបានផ្តួលរំលំដោយរបបដែលគាំទ្រដោយវៀតណាមកាលពីខែធ្នូឆ្នាំ១៩៨១ ហើយត្រូវបានបញ្ជូនទៅដាក់ពន្ធនាគារក្នុងទីក្រុងហាណូយអស់រយៈពេលមួយទសវត្សរ៍ ។

លោក ប៉ែន សុវណ្ណ បានមានប្រសាសន៍ថា "ខ្ញុំគិតថា នៅពេលនរណាម្នាក់កាន់តំណែងជានាយករដ្ឋមន្ត្រីជាង១០ឆ្នាំ បុគ្គលនោះ ឱ្យបង្កើតគំនិតផ្តាច់ការ" ។

លោកបានមានប្រសាសន៍បន្ថែមដោយទំនងជាសំដៅលើលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ថា" គាត់គិតថា គាត់អស្ចារ្យជាងគេគាត់ជាអ្នកសម្រេចចិត្តធ្វើអ្វីៗទាំងអស់គាត់មិនខ្វល់ហើយក៏មិនស្តាប់យោបល់របស់ពលរដ្ឋដែរ" ។

លោក គល់ បញ្ញា នាយកប្រតិបត្តិគណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) ជាសមាជិកដ៏លេចធ្លោមួយរូបរបស់សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោតបានលើកឡើងថា ញត្តិអំពាវនាវឱ្យមានការកំណត់អាណត្តិនេះនឹងដាក់ជូនលោក ហ៊ុន សែន នៅសប្តាហ៍នេះ ។

លោក គល់ បញ្ញា បានលើកឡើងទៀតថា អតីតនាយករដ្ឋមន្ត្រីចំនួនពីររូបមកពីគណបក្សហ្វ៊ុនស៊ិនប៉ិច ដែលធ្លាប់ធ្វើការជាមួយលោក ហ៊ុន សែន ក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ក៏បានបង្ហាញពីការគាំទ្ររបស់ខ្លួនចំពោះវិធានការនេះដែរ ប៉ុន្តែថាលោកមិនដឹងច្បាស់អំពីលោក ហ៊ុន សែន នោះទេ ។

លោក គល់ បញ្ញា បានមានប្រសាសន៍ថា "ព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ ក៏គាំទ្រញត្តិនេះដែរ ហើយខ្ញុំក៏បានហៅទូរស័ព្ទទៅឯកឧត្តម អ៊ឹង ហួត ដែរ ហើយគាត់បានប្រាប់ខ្ញុំថា វាមិនមែនជាតួនាទីរបស់គាត់ដែលត្រូវគាំទ្រញត្តិនេះទេ ប៉ុន្តែថាគាត់ធ្លាប់បានធ្វើយុទ្ធនាការមួយ ដើម្បីទាមទារឱ្យមានការកំណត់អាណត្តិនាយករដ្ឋមន្ត្រីកាលពីឆ្នាំ១៩៩៨" ។

លោក គល់ បញ្ញា បានមានប្រសាសន៍បន្តទៀតថា "យើងមិនទាន់មានព័ត៌មានច្បាស់លាស់នៅឡើយទេ អំពីជំហររបស់គណបក្សប្រជាជនកម្ពុជា ហើយក៏មិនដឹងថា តើពួកគេគាំទ្រ ឬក៏អត់ដែរ" ៕ **ស៊ុយឈាង**

**Continued from Page 12**
## Ex-Prime Minister Makes...

says that he is the person to decide all things and does not care or listen to the people's opinions," he added, in an apparent refer- ence to Mr. Hun Sen.

Koul Panha, executive director of the Committee for Free and Fair Elections in Cambodia, a prominent member of the ERA, said that a petition calling for the term limits would be lodged with Mr. Hun Sen this week.

Mr. Panha said the two Funcinpec prime ministers who served alongside Mr. Hun Sen in the 1990s have also indicated their support for the measure but that he was unsure about Mr. Hun Sen.

"Prince Norodom Ranariddh also supports this petition and I also called His Excellency Ung Huot, and he told me that it is not his place to support it, but that he had held a campaign to demand limits on prime ministers in 1998," Mr. Panha said.

**sovuthy@cambodiadaily.com**




LOWELL ELDER CARE
978-596-1111

# មជ្ឈមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល

345 Chelmsford St. Lowell, MA 01851/ — www.lowelleldercare.com

**អ្វីទៅជាមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល?**

គឺជាលំនៅដ៏កក់ក្តៅមួយ ដែលផ្តល់សេវាមានកម្មវិធីជាក់លាក់ដល់សហគមន៍បំណង គឺគាំទ្រឲ្យមនុស្សចាស់ជរាអាចរស់នៅដោយឯករាជ្យខ្លួនឯង និងជួយឲ្យមានសុខុមាលភាពផ្នែកផ្លូវកាយ ផ្លូវចិត្ត និងផ្នែកសង្គម ។ កម្មវិធីរបស់យើងធានានូវបរិស្ថានរស់នៅមួយប្រកបដោយសុវត្ថិភាព និងមានបរិយាកាសដូចជាផ្ទះរបស់ពួកគាត់ ។

**ទីតាំងនៃមណ្ឌល**

ទីតាំងអាចរកឃើញដោយងាយក្នុងអគារថ្មី ជាមួយនូវការតុបតែងរចនាបែបសិល្បៈខ្មែរយ៉ាងល្អប្រណិត ។ មានបន្ទប់ទទួលទានអាហារស្អាត និងមានពន្លឺគ្រប់គ្រាន់ បន្ទប់អានសៀវភៅ បន្ទប់កុំព្យូទ័រ បន្ទប់សម្រាក បន្ទប់មើលភាពយន្ត និងកន្លែងផ្សេងៗទៀតជាទីពេញចិត្តរបស់លោកអ្នក ។

**មណ្ឌលផ្តល់សេវាដល់មនុស្សចាស់**

- មានរថយន្តជូនដំណើរទៅវិញទៅមកពីផ្ទះលោកអ្នក
- ការពិនិត្យ និងថែទាំសុខភាព
- ការព្យាបាលតាមរយៈការហាត់ប្រាណ
- កិច្ចការសង្គម (ផ្តល់ការពិគ្រោះផ្ទាល់ខ្លួន និងក្រុមគ្រួសារ)
- ម្ហូបខ្មែរក្តៅៗ និងចំណីផ្សេងៗ
- ការហាត់ប្រាណសំរាប់សុខភាពរាងកាយ
- កម្មវិធីសិល្បៈ និងតន្ត្រី
- ការអប់រំពីសុខភាព
- ការពិភាក្សាលើព្រឹត្តិការបច្ចុប្បន្ន (និងការសំណេះសំណាលគ្នា)
- សកម្មភាព និងដំណើរកំសាន្តក្រៅមណ្ឌល

**Our Services**

- Door-to-Door Transportation
- Medical Care and Support
- Physical Therapy
- Social Worker
- Khmer Meals and Snacks
- Adaptive Physical Exercise
- Music Programs
- Health Educational Seminars
- Discussions on current events, (and times of reminiscing)
- Outdoor Field Trips



**សូមហៅលេខទូរស័ព្ទ (978) 596-1111**

**Accepting New Patients**

# មជ្ឈមណ្ឌលពេទ្យ និងទទួលព្យាបាល ស៊ី ប៊ី ស៊ី

**AT NEW LOCATION**

**ចាប់បើកហើយ**

## CBC Medical & Walk-In Center

*Serving the Lowell Community for over 20 years!*

Mon - Fri 8AM-4PM. **1st & 3rd Sat: 8AM-NOON.** 978-454-9703

**ទទួលអ្នកជំងឺថ្មី**

### Services:

- In House Lab & Blood Work
- Immunizations
- Physical Exams
- Emergency Room Follow-Ups
- Nebulizer & Asthma Treatments

- EKG Testing
- Wellness & Preventative Care
- Workers Comp Medical Treatment
- DOT Physicals
- Walk-Ins for Illness & Minor Injury

### Primary Care & Urgent Care Services

*ពេទ្យគ្រួសារ និងសង្គ្រោះបន្ទាន់*

- ពិនិត្យឈាមនៅមន្ទីរពិសោធន៏ក្នុងមជ្ឈមណ្ឌល
- ចាក់វ៉ាក់សាំងការពារ
- ពិនិត្យរាងកាយ
- តាមដានពិនិត្យនៅបន្ទប់ព្យាបាលបន្ទាន់
- ហ្វឹកហាត់ផ្នែកដកដង្ហើម

- ថតចលនាបេះដូង
- ថែទាំសុខភាពទូទៅសម្រាប់គ្រួសារ
- ទទួលព្យាបាលអ្នកទទួលគ្រោះថ្នាក់នៅកន្លែងធ្វើការ
- ពិនិត្យនិងផ្តល់លទ្ធផលបញ្ជាក់ដើម្បីទទួលសិទ្ធ
- អាចពិនិត្យពេលឈឺ និងគ្រោះថ្នាក់ដោយមិនបាច់ណាត់ជួប

**Cambodian Speaking Staff** *(បុគ្គលិកនិយាយភាសាខ្មែរ)*

**យើងខ្ញុំមានសេចក្តីសោមនស្សរីករាយប្រាប់ជូនលោកអ្នក**
**យើងខ្ញុំនឹងផ្លាស់ទៅទីតាំងថ្មី**

*នៅផ្លូវ16 Pine St Unit #5 Lowell, MA 01851*
*នាថ្ងៃទី 21 កក្កដា ឆ្នាំ 2014*

*អរគុណដល់លោកអ្នកទាំងអស់គ្នាដែលបានមកជួបយើង នៅតូប នាពិធីបុណ្យអុំទូកអាស៊ីអាគ្នេយ៍ ឆ្នាំ២០១៤*
**ចាក់ថ្នាំ Flu មកដល់ហើយ*



**CBC Staff And Dr. Joshi Welcome You!**

**បុគ្គលិក និងវេជ្ជបណ្ឌិត យូស៊ី សូមស្វាគមន៏លោកអ្នក!**




Like us on facebook

**CALL TO MAKE AN APPOINTMENT TODAY**

*(សូមទូរស័ព្ទដើម្បីណាត់ជួប)*

**978-454-9703**

# 16 Pine Street Unit #5 Lowell, MA 01851